# ក ម្ម ផ ល


រៀបរៀងដោយ

**ភិក្ខុ ចិន ភេន ឥន្ទបញ្ញោ**

វត្តពោធិវង្ស

ប្រទេសបារាំង



ព.ស.២៥៤៥ គ.ស.២០០០

# អារម្ភកថា

*ព្រះត្រៃលក្ខណ៍ អរិយសច្ច បដិច្ចបមុប្បាទ សុទ្ធតែជាទ្រឹស្តីធំៗក្នុងព្រះពុទ្ធសាសនា។ កម្មផល ក៏ជាទ្រឹស្តីធំៗ ក្នុងពុទ្ធសាសនាដែរ។ បើគ្មានកម្មផល ពុទ្ធសាសនាក៏គ្មាន។ បុគ្គលអ្នកមិនជឿកម្មផល មិនមែនជាពុទ្ធសាសនិកទេ បុគ្គលអ្នកជឿកម្មផលសើរៗ ឬជឿជ្រុល ក៏មិនមែនជាពុទ្ធសាសនិកជនដែរ ព្រោះសា សនាអន្តិរ្ថិយ៍មានទ្រឹស្តីកម្មផលស្រដៀងគ្នានេះដែរ។ ហេតុនេះ បុគ្គលណាប្តេជ្ញាខ្លួនថាជាពុទ្ធសាសនិកជន បុគ្គលនោះត្រូវសិក្សាត្រូវបដិបត្តិតា មទ្រឹស្តីកម្មផលរបស់ព្រះពុទ្ធឲ្យបានត្រឹមត្រូវ បើមិនដូចនោះទេ នឹងទៅជាសាសនិកជនរបស់ពួកអន្តិរ្ថិយ៍ដោយមិនដឹងខ្លួន។*

*ដើម្បីទប់ស្កាត់អ្នកកាន់ពុទ្ធសាសនា កុំឲ្យក្លាយខ្លួនជាពួកអន្តរ្ថិយ៍ ទើបខ្ញុំសរសេរកូនសៀវភៅទ្រឹស្តីកម្មផល នេះឡើង។ ខ្ញុំសង្ឃឹមថា កូនសៀវភៅនេះ អាចជួយបំភ្លឺ ផ្លូវបដិបត្តិដល់លោកអ្នកបានខ្លះជាពុំខាន។*

*ខ្ញុំសូមឧទ្ទិសបុណ្យកុសលដែលកើតអំពីកូនសៀវភៅនេះដល់សព្វសត្វទាំងអស់។ សូមសព្វសត្វទាំងអស់ កុំធ្វើកម្មអាក្រក់ ខំធ្វើកម្មល្អ ហើយព្យាយាមសម្អាតចិត្តរបស់ខ្លួនឲ្យស្អាតផូរផង់ ដោយប្រពៃចុះ។*

*វត្តពោធិវង្ស, ថ្ងៃទី ១៣ ខែមេសា ឆ្នាំ២០០០*

**ភិក្ខុ ចិន តេន ឥន្ទប្បញ្ញោ**

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

# កម្មផល

កម្មផល ជាទ្រឹស្តីធំមួយស្មុគ្រស្មាញណាស់ បើគេមិនខំសិក្សាឲ្យយល់ច្បាស់ទេ គេមុខជាមិនជឿកម្មផល មិនជឿបាបបុណ្យ ហើយប្រព្រឹត្តខុសឆ្គង រឹតតែច្រើនឡើងៗ ជាហេតុនាំមកនូវសេចក្តីទុក្ខ ដល់ខ្លួនផង ដល់អ្នកដទៃផង។ បុគ្គលខ្លះយល់ថា កម្មគឺជាអំពើ ដែលគេធ្វើហើយពីជាតិមុន វាតាមមកឲ្យផលក្នុងជាតិបច្ចុប្បន្ន នេះ រីឯកម្មបច្ចុប្បន្ន គេភ្លេចឈឹង គេមិនគិត គេមិននិយាយផង។ បុគ្គលខ្លះយល់ថា កម្មគឺជាអំពើអាក្រក់ពីជាតិមុន ឬក៏ផលអាក្រក់ដែលគេបានទទួលក្នុងបច្ចុប្បន្ននេះ ត្រង់អំពើល្អឬផលល្អគេអត់បានយល់ថា ជាកម្មទេ។ ការយល់បែបនេះ ទុកជាការឃ្លៀងឃ្លាត មិនទាន់ត្រូវតាមអត្ថន័យរបស់ពាក្យថា កម្មក្នុងពុទ្ធសាសនាទេ។ គេត្រូវតែសិក្សាទ្រឹស្តីកម្មផលឲ្យបានយល់ច្បាស់។

**កម្ម** គឺជាអំពើ[1] ដែលគេធ្វើដោយកាយវាចាចិត្ត។ កម្ម ដែលគេគេធ្វើដោយកាយហៅថា កាយកម្ម គេធ្វើដោយវាចាហៅថា វចីកម្ម គេធ្វើដោយចិត្តហៅថា មនោកម្ម ។អំពើ ដែលគេរាប់ថាជាកម្មពិតប្រាកដបាន លុះណាតែមានចេតនា (ចិត្ត) ចូលរួមផង ព្រោះព្រះពុទ្ធសម្តែងទុកថា "**ចេតនាហំ ភិក្ខវេ កម្មំ វទាមិ** *ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា ចេតនាជាតួកម្ម* " ។ អំពើដែលមិនប្រកបដោយចេតនា មិនរាប់ថាជាកម្មទេ ឬអាចរាប់បញ្ចូលបានដោយអនុលោមតែប៉ុណ្ណោះ។ កម្មជារបស់កណ្តាលៗ ជាអតីតក៏មាន ជាបច្ចុប្បន្នក៏មាន ជាអនាគតក៏មាន ល្អក៏មាន អាក្រក់ក៏មាន ។ បើអំពើល្អ គេហៅថា កុសលកម្ម បើអំពើអាក្រក់គេហៅថា អកុសលកម្ម ។

## មាតរដ្ឋាន ខ្នាតសម្រាប់វាស់កម្មផល

អ្វី គឺសេចក្តីល្អ អ្វី គឺសេចក្តីអាក្រក់ អំពើដូចម្តេចល្អ អំពើដូចម្តេចអាក្រក់ ? សំណួរនេះ ចម្លើយមិនសូវដូចគ្នាទេ អ្នកខ្លះឆ្លើយអីចេះ អ្នកខ្លះឆ្លើយអីចុះ ដូចនេះ កម្មដូចម្តេចល្អ កម្មដូចម្តេចអាក្រក់ គង់ពិបាកឆ្លើយ។ ប៉ុន្តែព្រះពុទ្ធសម្តែងថា កម្មណាឲ្យផលជាទុក្ខក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ កម្មនោះ អាក្រក់ កម្មណាឲ្យផលជាសុខត្រជាក់ក្សេមក្សាន្ត ក្នុងកាលជាខាងក្រោយ កម្មនោះល្អ។ ព្រះពុទ្ធទ្រង់ទតឃើញវែងឆ្ងាយ ហើយព្រះអង្គយក ផលក្នុងកាលជាខាងក្រោយជាគោល នេះជាខ្នាតមួយ។ យើងអធិប្បាយពង្រីកថា កម្មណាឲ្យផលជាសុខក្នុងពេលកំពុងធ្វើ ហើយឲ្យផលជាសុខក្នុងកាលជាក្រោយទៀត កម្មនោះល្អលេខ ១ កម្មណាឲ្យផលជាទុក្ខក្នុងពេលកំពុងធ្វើ តែឲ្យផលជាសុខក្នុងកាលជា ខាងក្រោយ កម្មនោះល្អលេខ ២ ។ កម្មណាឲ្យផលជាទុក្ខក្នុងពេលកំពុងធ្វើ ហើយឲ្យផល ជាទុក្ខក្នុងកាលជាក្រោយទៀត កម្មនោះអាក្រក់លេខ ១ កម្មណាឲ្យផលជាសុខក្នុងពេលកំពុងធ្វើ តែឲ្យផលជា ទុក្ខក្នុងកាលជាខាងក្រោយ កម្មនោះអាក្រក់លេខ ២ ។

---

[1] *ធ្វើ, អំពើ, អំពើ។ ពីដើមគេប្រើ អំពើ ឥឡូវគេប្រើ ទង្វើ។*

ដូចនេះ បុគ្គលអ្នកធ្វើអំពើអាក្រក់ បើវាមិនទាន់ឲ្យផលកុំសប្បាយរីករាយពេក វាមិនឥតផលទេ គង់តែជួប គ្រាន់តែចាំពេលវេលារបស់វាតែប៉ុណ្ណោះ។ ឯបុគ្គលអ្នកធ្វើអំពើល្អក៏កុំតូចចិត្តថាមិនមែនជាឥតផលទេ វានឹងចេញជាផ្លែផ្កា ឆ្ងាញ់ពិសានៅពេលខាងក្រោយ ជាពុំខាន។

*ព្រះពុទ្ធអនន្តញ្ញាណ បានសម្តែងទុកថា៖*

ចាបោបិ បស្សតិ ភទ្រំ យាវ ចាបំ ន បច្ចតិ
យទា ច បច្ចតី ចាបំ អថ ចាចានិ បស្សតិ
ភទ្រានិ បស្សតី ចាបំ អថ ភទ្រំ ន បច្ចតិ
យទា ច បច្ចតី ភទ្រំ អថ ភទ្រានិ បស្សតិ។

*ដរាបណាអំពើអាក្រក់មិនទាន់ឲ្យផល ដរាបនោះ មនុស្សអាក្រក់ឃើញថា អំពើអាក្រក់នោះ ថាល្អ តែពេលណាអំពើអាក្រក់នោះថាពិតមែន។ ដរាបណា អំពើល្អមិនទាន់ឲ្យផល ដរាបនោះ មនុស្សល្អ ឃើញអំពើល្អនោះថាមិនល្អទេ តែពេលណា អំពើល្អវាឲ្យផល ពេលនោះទើបមនុស្សល្អ ឃើញអំពើល្អនោះ ថាល្អពិតមែន* ២។

ម៉្យាងទៀតអំពើណានាំឲ្យ កិលេស លោភៈ ទោសៈ មោហៈ កើតឡើង អំពើនោះអាក្រក់ ឬថា អំពើណានាំឲ្យ **កិលេស តណ្ហា មានៈ ទិដ្ឋិ** កើតឡើង អំពើនោះអាក្រក់។ អំពើណានាំឲ្យ **កិលេស លោភៈ ទោសៈ មោហៈ** ថយចុះ អំពើនោះល្អ។ នេះជាខ្នាតសម្រាប់វាស់មួយទៀត។ ខ្នាតនេះល្អខ្ពង់ខ្ពស់ ហើយងាយចំណាំផង។

## កម្ម ២ យ៉ាង

កម្ម គឺអំពើ មានច្រើនយ៉ាងណាស់ តែបើពោលដោយខ្លី កម្មមាន ២ យ៉ាងគឺ៖

១- **អកុសលកម្ម** *កម្មអាក្រក់ ។*

២- **កុសលកម្ម** *កម្មល្អ ។*

មានឧទាហរណ៍ដូចតទៅនេះ៖

## អកុសលកម្មមាន ១០ យ៉ាង

ក) ចាត់ជា កាយកម្ម ៣ គឺ៖

១-**បាណាតិបាត** *អំពើបៀតបៀន ឬសម្លាប់សត្វដទៃ។*

២-**អទិន្នាទាន** *អំពើគៃបន្លំ លួច ឬប្លន់យកទ្រព្យសម្បត្តិអ្នកដទៃ។*

---

២ *សុត្តបិដក, ខុទ្ទកនិកាយ, ខុទ្ទកបាឋទិ, ៥២/១៩/៤៧ ។*

៣-កាមេសុ មិច្ឆាចារ *អំពើខុសឆ្គងក្នុងកាមទាំងឡាយ គឺកន្ទងប្រពៃណី ប្ដី ប្រពន្ធ កូន ចៅ អ្នកដទៃ។*

ខ) ចាត់ជា វចីកម្ម ៤ យ៉ាងគឺ៖

១-មុសាវាទ *ពាក្យសម្ដីកុហក ឬបញ្ឆោត។*

២-បិសុណាវាទ *ពាក្យសម្ដីញុះញង់ អុជអាល។*

៣-ផរុណាវាទ *ពាក្យសម្ដីទ្រគោះ ចាត់ដោត។*

៤-សម្ផប្បលាបវាទ *ពាក្យសម្ដីពេយពាយឥតប្រយោជន៍។*

គ) ចាត់ជា មនោកម្ម ៣ គឺ៖

១-អភជ្ឈា *គំនិតលោភលន់ចង់បានទ្រព្យសម្បត្តិអ្នកដទៃ។*

២-ព្យាចាទ *គំនិតបៀតបៀនប្រទូសរ៉ាយអ្នកដទៃ។*

៣-មិច្ឆាទិដ្ឋិ *គំនិតយល់ខុសចាកគន្លងធម៌ថា គ្មានបុណ្យ គ្មានបាប ឬម៉ែឪ គ្មានគុណជាដើម។*

## កុសលកម្មមាន ១០ យ៉ាង

ក) ចាត់ជា កាយកម្ម ៣ គឺ៖

១-ចាណាតិចាតា វេរមណី *វៀរចាកអំពើបៀតបៀនឬសម្លាប់សត្វដទៃ។*

២-អទិន្នាទានា វេរមណី *វៀរចាកអំពើគៃបន្លំ លួច ឬ ប្លន់យកទ្រព្យសម្បត្តិអ្នកដទៃ។*

៣-កាមេសុ មិច្ឆាចារា វេរមណី *វៀរចាកអំពើខុសឆ្គងក្នុងកាមទាំងឡាយ គឺគន្លងប្រពៃណី ប្ដី ប្រពន្ធ កូន ចៅ អ្នកដទៃ។*

ខ) ចាត់ជា វចីកម្ម ៤ គឺ ៖

១-មុសាវាទា វេរមណី *វៀរចាកពាក្យសម្ដីកុហក ឬបញ្ឆោត។*

២-បិសុណាយ វាចាយ វេរមណី *វៀរចាកពាក្យសម្ដីញុះញង់ អុជអាល។*

៣-ផរុសាយ វាចាយ វេរមណី *វៀរចាកពាក្យទ្រគោះ ចាក់ដោត។*

៤-សម្ផប្បលាចា វេរមណី *វៀរចាកពាក្យសម្ដីពេយពាយឥតប្រយោជន៍។*

គ) ចាត់ជា មនោកម្ម ៣ គឺ ៖

១-អនភិជ្ឈា *មិនគិតលោភលន់ចង់បានទ្រព្យសម្បត្តិអ្នកដទៃ។*

២-អព្យាចាទ *មិនគិតបៀតបៀនប្រទូសរ៉ាយអ្នកដទៃ។*

៣-សម្មាទិដ្ឋិ *គំនិតយល់ឃើញត្រូវតាមគន្លងធម៌ថាមានបាប មានបុណ្យ ឬម៉ែឪមានគុណជាដើម។*

## ផលនៃកម្ម

តាមច្បាប់ធម្មជាតិ បើមានហេតុ ត្រូវតែមានផល បើហេតុរលត់ ផលត្រូវតែ រលត់ដែរ។ ក្នុងទីនេះ កម្មគឺអំពើទុកជាហេតុ នាំឲ្យមានផ្លែផ្កាគឺផល ដូចនេះ អំពើដែលគេ បានធ្វើ ហើយ ត្រូវតែមានផល គេត្រូវតែទទួលយកផលនោះ។ **យាទិសំ វប្បតេ ពីជំ** *គេសាបព្រោះពូជ យ៉ាងណា* **តាទិសំលភតេ ផលំ** *គេត្រូវតែបានផ្លែផ្កាយ៉ាងនោះ* ។ បើគេដាំអម្ពិល គេត្រូវបានផ្លែជូរ បើគេដាំអំពៅ គេត្រូវបានរសជាតិផ្អែម។ **កល្យាណការី កល្យាណំ** *អ្នកធ្វើល្អត្រូវបានល្អ* **បាបការីច បាបកំ** *អ្នកធ្វើអាក្រក់ត្រូវបានអាក្រក់*។ ការដែលគេបានឃើញ ផលផ្ទុយគ្នា មកពីគេភាន់ច្រឡំ ពុំបានសង្កេតពិនិត្យ និងសិក្សាឲ្យបានច្បាស់លាស់ ឬក៏មកពីមានកម្មផ្សេងៗទៀតចូលមកជ្រៀតជ្រែកឲ្យផល ព្រោះដល់វេនរបស់វាហើយ។

## ផលក្រៅ ផលក្នុង

ទ្រព្យសម្បត្តិ សក្តិយសជាដើម ជាផលខាងក្រៅ ព្រោះវាជារបស់មើលឃើញងាយ នរណាៗក៏មើលឃើញបាន សូម្បីតែមនុស្សអប្បឥតបញ្ញាក៏មើលឃើញបានដែរ។ មនុស្សបញ្ញារាក់យល់ថា ការបានទ្រព្យសម្បត្តិ សក្តិយសជាផលនៃអំពើល្អ តែសេចក្តីពិត វាមិនសុទ្ធតែដូចនោះទាំងអស់ទេ។ ទ្រព្យសម្បត្តិ កើតឡើងដោយសារអំពើ ល្អ គឺការប្រឹងប្រែង ធ្វើការងារ ការចេះចាត់ចែងថៃទាំទុកដាក់ និងការសន្សំសំចៃជាដើមក៏មាន ឬទ្រព្យសម្បត្តិ អាចកើតឡើងដោយសារអំពើអាក្រក់ លួចឆក់ សង្កត់សង្កិនរឹបជាន់យក របស់អ្នកដទៃ គៃបន្លំ លក់ដូរ គ្រឿងញៀន អាភៀន កញ្ឆា ស្រាស្រី ជាដើមក៏មានដែរ។ សក្តិយសក៏ដូចគ្នាដែរ គឺវាកើតឡើងដោយសារអំពើល្អ គេខំធ្វើការងារ ជាដើមក៏មាន ឬសក្តិយស អាចកើតឡើងដោយសារអំពើអាក្រក់ អគតិធម៌ ប្រកាន់បក្សពួក ឬដោយសារ តថ្លៃទិញដូរ គ្នាត្រង់ៗក៏មាន។ សក្តិយសកន្លែងខ្លាញ់ៗ សម័យសព្វថ្ងៃនេះ ច្រើនតែកើតឡើងដោយសារ បក្សពួក និងទិញដូរគ្នា...។

សក្តិយសដ៏អប្រិយនេះហើយ ដែលនាំឲ្យប្រទេ សជាតិលិចលង់ ផុងងើបមិនរួច ទៅមុខមិនបាន រឿងនេះគួរឲ្យអាម៉ាស់ និងឈឺចាប់ជាទីបំផុត។ ក្នុងទំនងដូចគ្នា ការថយចុះនៃទ្រព្យសម្បត្តិ ឬសក្តិយស អាចកើតឡើងដោយសារអំពើល្អ ដូចជាធ្វើបុណ្យទាន ច្រើនពេក ជួយកសាងជាតិច្រើនពេក ទ្រព្យសម្បត្តិអាចថយចុះ ឬធ្វើការស្អាតស្អំ មិនសមមិន គាប់ចិត្តចៅហ្វាយពុករលួយ អាចថយសក្តិយសក៏មាន។ ម៉្យាងទៀត ទ្រព្យសម្បត្តិ និងសក្តិយសថយចុះ ព្រោះអំពើអាក្រក់ លេងល្បែងអបាយមុខ ឬមិនខំប្រឹង ធ្វើការងារជាដើមក៏មាន។ ហេតុនេះ នឹងយកផលខាងក្រៅ ទុកជាគ្រឿងកំណត់អំពើល្អ ជាការមិនត្រឹមត្រូវបាន ទាំងអស់ទេ។

សេចក្តីស្អាត និងសេចក្តីសៅហ្មងនៃចិត្ត ចាត់ជាផលខាងក្នុង អំពើល្អតែងតែកើត សេចក្តីស្អាតក្នុងចិត្ត ឯអំពើអាក្រក់តែងតែកើតសេចក្តីសៅហ្មងក្នុងចិត្ត ជាដរាប។ សេចក្តីស្អាត និងសេចក្តីសៅហ្មងដែលកើតក្នុងចិត្ត

នេះហើយ ជាផលពិតប្រាកដរបស់កម្ម ធ្វើពេលណា បានពេលនោះភ្លាម ហើយវានិងបន្តឲ្យផលទៅមុខទៀត ប្រៀបដូចជាគេដាំ ដើមឈើដូច្នោះ វាចេះតែបន្តឲ្យផលរឿយៗ រហូតទាល់តែអស់សមត្ថភាព។ កម្មវាឲ្យផលវែងឆ្ងាយណាស់ មិនមែនតែជាតិបច្ចុប្បន្ននេះមួយទេ ច្រើនកោដិកប្បជាតិតទៅមុខទៀត។

បុគ្គល អ្នកមិនបានសិក្សារឿងកម្មផលនេះឲ្យហ្មត់ចត់មើលមិនចប់ចុងចប់ដើម ច្រើនតែភាន់ច្រឡំថា ធ្វើបុណ្យមិនឃើញបានបុណ្យហើយធ្វើបាបមិនឃើញបានបាប អ្នកខ្លះធ្វើតែអំពើល្អ ប៉ុន្តែមិនឃើញបានអ្វី ឃើញបានតែទុក្ខលំបាក...។

សេចក្តីនេះ សមនិងព្រះពុទ្ធដីកាថា ៖

**មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**

**យទា ច បច្ចតិ បាបំ អថ ទុក្ខំ និគច្ឆតិ។**

*អំពើអាក្រក់ មិនទាន់ឲ្យផល ដរាបណា ជនពាលសំគាល់ថា អំពើអាក្រក់ ដូចទឹកឃ្មុំ លុះពេលណា អំពើអាក្រក់វាឲ្យផល ពេលនោះ ជនពាលកើតទុក្ខធំយំស្តាយក្រោយ*[៣]។

ហេតុនេះ បុគ្គលកុំគប្បីប្រញាប់បដិសេធបាប បុណ្យ ត្រូវសិក្សាពិចារណាឲ្យបាន ហ្មត់ចត់ ជាមុនសិន កុំជឿត្រឹមតែបញ្ញារបស់ខ្លួន ត្រូវជឿបញ្ញារបស់អ្នកប្រាជ្ញ ដូចជាព្រះពុទ្ធ ជាដើមផ្សំផង បើធ្លាក់ខ្លួនជមិច្ឆាទិដ្ឋិហើយ មិនងាយរើខ្លួនឡើងវិញបានទេ។

## នរណាធ្វើឲ្យសត្វលោកប្លែកគ្នា

មនុស្សយើងកើតមកមិនដូចគ្នាទេ អ្នកខ្លះកើតក្នុងខ្ទម អ្នកខ្លះកើតក្នុងផ្ទះថ្ម ក្នុងប្រាសាទ សូម្បីតែកើតក្នុងផ្ទះថ្មដូចគ្នា រូបរាងក៏មិនដូចគ្នា ចិត្តថ្លើមក៏មិនដូចគ្នាទៀត តើនរណាធ្វើឲ្យសត្វ លោកមិនដូចគ្នាយ៉ាងនេះ?

សុភមាណព បានទូលសួរព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុធ្វើឲ្យសត្វលោកប្លែកគ្នា អ្នកខ្លះមាន អ្នកខ្លះក្រ អ្នកខ្លះល្អ អ្នកខ្លះអាក្រក់ អ្នកខ្លះអាយុវែង អ្នកខ្លះអាយុខ្លី ...? ព្រះពុទ្ធទ្រង់ត្រាស់ថា **កម្មស្សកោ មាណវសត្តា កម្មទាយាទា កម្មយោនី កម្មពន្ធុ កម្មបដិសរណា កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** *ម្នាកមាណព សត្វទាំងឡាយ មានកម្មជារបស់ខ្លួន ជាទាយាទនៃកម្ម (គឺជាអ្នកទទួលមត៌កនៃកម្ម ) មានកម្មជាកំណើត មានកម្មជាផៅពង្ស (ញាតិសន្តាន) មានកម្មជាទីពឹង អាស្រ័យ កម្មជាអ្នកចាត់ចែងសត្វលោកឲ្យអាក្រក់ល្អ*[៤]។

តាមការត្រាស់ដឹងរបស់ព្រះពុទ្ធនេះ បញ្ជាក់ថា មិនមានព្រហ្ម ឬព្រះអាទិទេពអង្គណា ជាអ្នកកសាង សត្វលោកទេ គឺពិតជាកម្មនេះឯងជាអ្នកកសាងសត្វលោក ។ រឿងនេះ យើងអាចសង្កេតមើលក្នុងជីវិត ប្រចាំថ្ងៃរបស់យើងបាន ខ្ជិល និងឧស្សាហ៍ តើឲ្យផលខុសគ្នា ដូចម្តេច? កាច និងស្លូត តើឲ្យផលខុសគ្នាយ៉ាងម៉េច អ្នកផង គេស្អប់យើង កើតមកពីអ្វី? គេរាប់អានយើងតើមកពីអ្វី មកពីព្រះឥន្ទ ព្រះព្រហ្ម ឬមកពីកម្មគឺអំពើអាក្រក់ល្អរបស់យើង គិតតែប៉ុណ្ណឹងទៅគង់យល់បាន។

---

[៣] *សុត្តន្តបិដក ខុទ្ទនិកាយ ខុទ្ទកបាឋ ៥២/១៥/៣៥។*

[៤] *សុត្តន្តបិដក មជ្ឈិមនិកាយឧបរិបណ្ណាសក២៨/២៤/៥៦។*

*ព្រះពុទ្ធសម្ដែងថា* **កម្មស្សកោ** *មានកម្មជារបស់ខ្លួន។* តែសត្វលោក យល់ថា ខ្លួនជារបស់ខ្លួន ប្រពន្ធឬប្ដីជារបស់ខ្លួន កូនចៅរបស់ខ្លួន ទ្រព្យសម្បត្តិរបស់ខ្លួន...។ សត្វលោកយល់ដូចនេះ ត្រូវតាមការសន្មត តែមិនត្រូវតាមសេចក្ដីពិតទេ ព្រោះដល់ពេល ស្លាប់ គ្មានយកអ្វីដែលគេសំគាល់ថាជារបស់ខ្លួននោះ ទៅជាមួយបានទេ។ ព្រះពុទ្ធសម្ដែងថា កម្ម ពិតជារបស់ខ្លួន ព្រោះវាជាប់ទៅជាមួយខ្លួនរហូត ទៅទីណាកន្លែងណា កម្មតាមទៅ ជាមួយរហូត សូម្បីតែលះលោកនេះ (ស្លាប់) ក៏តាមជាប់ទៅជាមួយរហូតដែរ នេះបានពិតជារបស់ខ្លួនមែន។

**កម្មទាយាទា** *ជាទាយាទនៃកម្ម គឺជាអ្នកទទួលមត៌កនៃកម្ម។* កេរមត៌ក ដែលមាតាបិតា បម្រុងចែកឲ្យក្ដី ឬញាតិមិត្តចែកឲ្យក្ដី កេរមត៌កនោះ មិនទៀងទាត់ទេ ជួនកាលក៏បានទទួល ជួនកាលក៏មិនបានទទួល សូម្បីបានទទួលហើយ ក៏អាចត្រូវបាត់បង់ ទៅវិញបាន ដោយហេតុផ្សេងៗមានចោរលួចជាដើម។ តែមត៌កគឺកម្ម ដែលគេបានធ្វើហើយ គេត្រូវតែទទួលផលនៃកម្មនោះ ដោយខ្លួនឯងជាទៀងទាត់ នឹងឲ្យបុគ្គលឯទៀតទទួលជំនួស ពុំបានឡើយ។ ឧទាហរណ៍ ដោយសារកម្មអាក្រក់របស់គេ គេកើតមកជាបុគ្គលមានរោគាព្យាធិច្រើន គេត្រូវរងទុក្ខវេទនាយ៉ាងខ្លោចផ្សា តែគ្មានបុគ្គលណា សូម្បីតែប្រពន្ធ ឬកូន អាចជួយ ទទួលរំលែកទុក្ខនោះបានឡើយ ព្រោះគេជាទាយាទនៃ កម្មនោះ។

**កម្មយោនី** *មានកម្មជាកំណើត គឺកម្មជាអ្នកបង្កើតសត្វលោក។* បានសេចក្ដីថា បើមានកម្ម ត្រូវមានវិបាក គឺការកើតឡើងទៀត បើអស់កម្ម វិបាកគឺការកើតឡើងទៀតក៏អស់។ព្រះអរហន្តលោកលះកិលេសអស់ហើយ លោកធ្វើអ្វីមិនរាប់ថាជាកម្មបានទេ គ្រាន់តែជាកិរិយាប៉ុណ្ណោះ លោកអស់កម្មហើយ ដូចនេះ គ្មានវិបាកគឺការកើតឡើងទៀត បានទេ។ ផ្លូវលោក គេនិយាយថា មាតាបិតាជាអ្នកបង្កើត សត្វលោក ប៉ុន្តែផ្លូវធម៌ លោកនិយាយថា កម្មជាអ្នកបង្កើតសត្វលោក តែអាស្រ័យ មាតាបិតាជាទីកើត។

**កម្មពន្ធូ** *មានកម្មជាផៅពង្ស (ញាតិសន្ដាន)។* ញាតិសន្ដាន ជាមិត្តនិងគ្នាខ្លះ ជាសត្រូវនិងគ្នាខ្លះ ជួយគ្នាបានខ្លះ ជួយគ្នាមិនបានខ្លះ សូម្បីជួយគ្នាបាន ពេលខ្លះនៅឆ្ងាយ ពីគ្នាពេករកតែជួយគ្នាមិនទាន់ ហើយក្នុងវិស័យខ្លះទៀតជួយគ្នា មិនបានតែម្ដង ដូចជានៅ ពេលប្រឡងជាដើម។ ចំណែកកម្មដែលគេបានសាងទុក គឺជាញាតិយ៉ាងជិតស្និទ្ធបំផុត ហើយអាចជួយគ្រប់កាលៈទេសៈទាំងអស់។

**កម្មប្បដិសរណា** *មានកម្មជាទីពឹងអាស្រ័យ។* បងប្អូនញាតិមិត្ត យើងពឹងគេបាន មួយដង មួយកាល ពឹងគេរហូតមិនបានទេ សូម្បីមាតាបិតា យើងពឹងលោករហូតក៏មិនសូវល្អដែរ គេទិទៀនថា កូនអីចិ ញ៉ឹមមិនចេះធំ ...។ ចំណែកកម្មដែលគេបានកសាងហើយ តែងជាទីពឹង អាស្រ័យរបស់គេបាន គ្រប់ពេលវេលា គ្រប់ទីកន្លែង និងតទៅរហូត គ្រប់ៗជាតិ។

ជម្រាបមកដោយសង្ខេបប៉ុណ្ណោះ បញ្ជាក់ឲ្យឃើញថា កម្មមានតួនាទីសំខាន់ណាស់ ដែលគេត្រូវខំសាង ឲ្យបានល្អ។

## កម្ម ៤ យ៉ាង

**១-កម្មំ កណ្ហំ កណ្ហវិបាកំ** *កម្មខ្មៅមានវិបាក(ផល)ខ្មៅ។*

**២-កម្មំ សុក្កំ សុក្កវិបាកំ** *កម្មស មានវិបាកស។*

៣-**កម្មំ កណ្ហំ សុក្កំ កណ្ហសុក្កវិបាកំ** *កម្មខ្មៅខ្លះ កម្មសខ្លះ មានវិបាក ខ្មៅខ្លះ សខ្លះ។*

៤-**កម្មំ អកណ្ហំ អសុក្កំ អកណ្ហអសុក្កវិបាកំ កម្មក្ខយាយ សំវត្តតិ** *កម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅ ដើម្បីអស់កម្ម*[៥] *។*

ក្នុងព្រះសូត្រនេះ ព្រះសម្មាសម្ពុទ្ធទ្រង់យកពណ៌ជាគ្រឿងប្រៀបធៀប។ ពណ៌ខ្មៅ តំណាងឲ្យសេចក្ដីអាក្រក់ សេចក្ដីទុក្ខក្ដៅក្រហាយ ពណ៌ស តំណាងឲ្យសេចក្ដីល្អ សេចក្ដីសុខស្ងប់ត្រជាក់។ កម្មខ្មៅ បានដល់អកុសលកម្ម កម្មស បានដល់កុសលកម្ម។ បើគេធ្វើកម្មខ្មៅ គេត្រូវទទួលវិបាកខ្មៅ បើគេធ្វើកម្មស គេត្រូវទទួលវិបាកស បើគេធ្វើកម្មខ្មៅខ្លះ សខ្លះ លាយគ្នា គេត្រូវទទួលផលលាយគ្នាដែរ គឺ ទុក្ខខ្លះសុខខ្លះសើចខ្លះយំខ្លះ ផ្លាស់ប្ដូរគ្នារឿយៗ តាមអំពើដែលគេបានធ្វើ។ សត្វដែលនៅមានកម្ម ត្រូវតែអន្ទោល វិលវល់ក្នុងវដ្ដសង្សារ លិចអណ្ដែកៗ កើតស្លាប់ៗ ពីខ្ពស់មកទាប ពីទាបមកខ្ពស់ ពីមនុស្សទៅរក ...ពីមនុស្សទៅទេវតា ... សាចុះសាឡើងដូចជាគ្រាប់អង្ករនៅក្នុងឆ្នាំងដែលគេដាំទឹកឲ្យ ពុះ វាកព្រោលចុះឡើងៗដូចនោះដែរ។

## ត្រៃវដ្ដៈ

ធម៌ជាគ្រឿងវិលវល់ ក្នុងវដ្ដសង្សារ ហៅថា វដ្ដៈ។ វដ្ដៈមាន ៣ យ៉ាងគឺ ១-**កិលេស** ២-**កម្មវដ្ដ** ៣-**វិបាកវដ្ដ**។

១-**កិលេសវដ្ដ** *ធម៌ជាគ្រឿងវិលវល់គឺកិលេស បានដល់ អវិជ្ជា តណ្ហា។*

២-**កម្មវដ្ដ** *ធម៌ជាគ្រឿងវិលវល់គឺកម្ម បានដល់ សង្ខារ ភព។*

៣-**វិបាកវដ្ដ** *ធម៌ជាគ្រឿង វិលវល់គឺវិបាក បានដល់ វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា។*

ព្រោះមានកិលេសជាបច្ច័យ ទើបកើតកម្ម បើគ្មានកិលេសដូចព្រះអរហន្ត លោកអត់មានកម្មទេ ព្រោះមានកម្មជាបច្ច័យ ទើបកើតវិបាក មានជាតិ ជរា មរណៈ បន្តទៅទៀត បើគ្មានកម្មដូចព្រះអរហន្ត លោកអត់មានវិបាកទេ ជាតិ ជរា មរណៈ ក៏ចប់។

មនុស្សធម្មតា គេមិនឃើញទោសនៃការកើតទេ បើបានកូនមួយ ឬចៅមួយ គេបង្អួត ដាក់គ្នា គេសប្បាយរីករាយនឹងការកើត។ គេយល់ថា ការកើតមា នទុក្ខ ចំពោះតែអ្នកកើតជា កូនអ្នកក្រ បើកើតជាកូនអ្នកមានអត់មានទុក្ខទេ... កើតមកពិបាក ចំពោះអ្នកកើតជាមនុស្ស បើកើតជាទេវតាមានទៅពិបាកអីអ្វីៗ សុទ្ធតែជាទិព្វ...។ ចំណែកព្រះពុទ្ធ ព្រះអង្គឃើញ ច្បាស់ថា ការកើតជាដុំទុក្ខមួយដ៏ធំ ទោះបីកើតក្នុងភពណា កាមភព រូបភព អរូបភព ក្នុងត្រកូលថោកទាប ឬត្រកូលខ្ពង់ខ្ពស់យ៉ាងណាក្ដី សុទ្ធតែមានបញ្ហាទាំងអស់សុទ្ធតែនៅក្រោមច្បាប់ធម្មជាតិ **អនិច្ចំ ទុក្ខំ អនត្តា** ប្រែប្រួល ជាទុក្ខ មិនអាចត្រួតត្រាបាន។ ការកើតប្រៀបដូចជាដុំលាមក ទោះធំក្ដី តូចក្ដី សុទ្ធតែជារបស់ស្មោកគ្រោក មានក្លិន អសោច មិនគប្បីប៉ះពាល់ ត្រូវតែគេចឲ្យផុត។

---

[៥] *សុត្តន្តបិដក អង្គុត្តរនិកាយចតុក្កនិបាត៤៣/២២៩/៨២*

## វិធីបញ្ចប់វដ្ដៈ

វិធីបញ្ចប់នូវវដ្ដៈ ធម៌ជាគ្រឿងវិលវល់ ព្រះទសពលសម្ដែងថា ត្រូវកសាងកម្មប្រភេទ ទី ៤ គឺ កម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម។ ដូចម្ដេច កម្មមិនខ្មៅ មិនស ? គឺចេតនា ដើម្បីលះនូវកម្មខ្មៅ និងកម្មស។ បានសេចក្ដីថា ធ្វើកម្មអ្វី កុំឲ្យមានចិត្តប្រកបដោយ អវិជ្ជា និងតណ្ហា កុំប្រាថ្នាចង់បានជានេះជានោះ ធ្វើដើម្បីគោល ដៅតែមួយ គឺការរំលត់ទុក្ខ។ ម៉្យាងទៀតការបដិបត្តិម៉ត់ចត់ ត្រឹមត្រូវតាមផ្លូវប្រកបដោយអង្គ ៨ ដ៏ប្រសើរក្ដី ចេតនាក្នុងចតុមគ្គញ្ញាណក្ដី ឈ្មោះថាកម្មមិនខ្មៅ មិនស មានវិបាកមិនខ្មៅ មិនស ប្រព្រឹត្តទៅដើម្បីអស់កម្ម។ បើអស់កិលេស អស់កម្ម បើអស់កម្ម អស់វិបាក អស់ជាតិ ជរា មរណៈ វដ្ដៈ លែងវិលតទៅទៀតបានហើយ។

## កម្ម ១២ យ៉ាង

ទ្រឹស្ដីកម្មផល ស្មុគ្រស្មាញណាស់ មានស្រាល មានធ្ងន់ មានមុន មានក្រោយ មានជួបគ្នា មានប្រឆាំងគ្នា មានទាមទារពេលវេលាឲ្យផល មិនមែនត្រឹមតែមួយជីវិតទេ ច្រើនជីវិតច្រើនជាតិណាស់ បើយើងគិតពិ ចារណាខ្លីៗ ប្រើពេលវេលាខ្លីៗ កម្មឲ្យផល មិនទាន់បានសព្វគ្រប់ទេ។ រឿងកម្មផល ជាវិស័យរបស់ព្រះពុទ្ធ មិនមែនជាវិស័យរបស់ យើងទេ ប៉ុន្តែ បើយើងខំសិក្សា យើងនឹងកើតបញ្ញាភ្លឺស្វាងគ្រាន់បើដែរ ល្មមជឿកម្មផល និង បដិបត្តិទៅបានប្រយោជន៍សុខ យ៉ាងសមរម្យ។

## កម្មឱ្យផលតាមកិច្ច៤ យ៉ាង

១-**ជនកកម្ម** *កម្មមានកិច្ចជាអ្នកបង្កើត ជាតួនាំសត្វឲ្យកើតក្នុងកាមភព រូបភព អរូបភព។*

**២-ឧបត្ថម្ភកកម្ម** *កម្មមានកិច្ចជ្រោមជ្រែង បើជនកកម្ម នាំឲ្យកើតក្នុងកន្លែងល្អ ជួយជ្រោមជ្រែងឲ្យរឹតតែល្អឡើង បើជនកកម្ម នាំឲ្យកើតក្នុងកន្លែងអាក្រក់ ជួយជ្រោមជ្រែង ឲ្យរឹតតែអាក្រក់ថែមទៀត។*

៣-**ឧបបីឡកកម្ម** *កម្មមានកិច្ចបៀតបៀន គឺបន្ថយផលនៃជនកកម្ម បើជនកកម្ម នាំឲ្យកើតក្នុងកន្លែងសុខច្រើនបន្ថយឲ្យមានសុខតិច បើជនកកម្ម នាំឲ្យកើតកន្លែងទុក្ខច្រើន បន្ថយឲ្យមាន ទុក្ខតិច។*

៤-**ឧបឃាតកកម្ម** *កម្មមានកិច្ចផ្ដាច់បង់នូវជនកកម្មនិ ងកម្មដទៃ ហើយឲ្យផលខ្លួនឯងជំនួស ឧទាហរណ៍ សម្លាប់សត្វផង សម្លាប់មនុស្សផង កម្មគឺការ សម្លាប់មនុស្ស ផ្ដាច់បង់ នូវផលនៃកម្មគឺការសម្លាប់សត្វ ហើយឲ្យផលខ្លួនឯងជំនួសវិញ*

*បើចំរើនឈានបានសម្រេច ចាប់តាំងពីបឋមជ្ឈានរហូតបានដល់ចតុត្ថជ្ឈាន ចតុត្ថជ្ឈាន ផ្តាច់បង់នូវផលនៃឈានខាងដើម ហើយឲ្យផលខ្លួនឯងជំនួសវិញ។*

*អធិប្បាយបន្ថែម ៖*

*ជនកកម្មផ្នែកល្អ* នាំឲ្យកើតក្នុងត្រកូលខ្ពង់ខ្ពស់មានទ្រព្យសម្បត្តិច្រើន កើតហើយ គេមិនប្រមាទ ខំយកចិត្តទុកដាក់ធ្វើការងារល្អតទៅទៀត (នេះជាឧបត្ថម្ភកកម្ម ) គេរឹតតែមានទ្រព្យសម្បត្តិច្រើនទៀត។ កើតហើយគេប្រហែសធ្វេស ខ្ជិលធ្វើការងារ (នេះជាឧបបីឡកកម្ម ) ទ្រព្យសម្បត្តិក៏អស់ថយចុះ ។ កើតហើយគេប្រមាទគិតតែលេង ល្បែងអបាយមុខ (នេះជាឧបឃាតកកម្ម) ទ្រព្យសម្បត្តិក៏វិនាសអស់រលីង។

*ជនកកម្មផ្នែកអាក្រក់* នាំឲ្យទៅកើតក្នុងត្រកូលទន់ទាប ក្រទ្រព្យសម្បត្តិ កើតហើយ គេខ្ជិលធ្វើការងារ គិតតែលេងល្បែងអបាយមុខ (នេះជាឧបត្ថម្ភកកម្ម) គេរឹតតែហិនហោច លិចលង់តទៅទៀត។ កើតហើយគេមិនសូវខ្ជិល ខិតខំធ្វើការងារ (ឧបបីឡកក្ម) គេក៏មានទ្រព្យសម្បត្តិយ៉ាងមធ្យម ប្រទ្បាំគេប្រទ្បាំងបាន។ កើតមកហើតគេខំរៀនសូត្រមាន ការចេះដឹងច្រើន ហើយខំយកចិត្តទុកដាក់ធ្វើការងារថែមទៀត (ឧបឃាតកកម្ម) គេក៏បាន ទទួលមុខតំណែងខ្ពង់ខ្ពស់ ហើយមា នទ្រព្យសម្បត្តិថែមទៀត។ អ្នកជឿកម្មផល ត្រូវយល់ និងអនុវត្តន៍តាមទ្រឹស្តីនេះ។

## កម្មឱ្យផលតាមលំដាប់មុនក្រោយមាន៤ យ៉ាង

១-**គរុកម្ម** *កម្មមានទម្ងន់* ផ្នែកអកុសលបានដល់អនន្តរិយកម្ម សម្លាប់មាតា សម្លាប់បិតា សម្លាប់ព្រះអរហន្ត ញ៉ាំងព្រះលោហិតនៃព្រះពុទ្ធឲ្យកើតឡើង និងការបំបែកសង្ឃ ផ្នែកកុសលកម្ម បានដល់មហគ្គតកម្ម គឺ សមាបត្តិ ៨ រូបជ្ឈាន ៤ អរូបជ្ឈាន ៤ ។ គរុកម្មឲ្យផល មុនកម្មឯទៀតទាំងអស់។

**២-អាសន្នកម្ម** *កម្មដែលគេធ្វើហើយពេលជិតស្លាប់* ដូចជាកូនចៅ ឬ ញាតិមិត្តគេជួយចាត់ចែងរៀបចំជាកិច្ចបុណ្យជូនក្តី ឬការនឹកដល់កម្មចាស់ដែលធ្លាប់ធ្វើ ហើយក្តីហៅថា អាសន្នកម្ម។ បើគ្មានគរុកម្មទេ អាសន្នកម្មត្រូវឲ្យផលមុន។

៣-**អាចិណ្ណកម្ម** *(ឬពហុលកម្ម) កម្មដែលគេធ្វើហើយធ្វើទៀតរឿយៗ* ទៅជាទម្លាប់ ជាផ្ទត់គំនិតក្តី ឬកម្មដែលគេធ្វើតែម្តងទេ ប៉ុន្តែចិត្តនៅតែចង់ចាំនឹកមិនភ្លេចក្តី ហៅថា អាចិណ្ណកម្ម ត្រូវឲ្យផលមុន។

៤-**កដត្តាកម្ម** *កម្មដែលគេធ្វើដោយឥតចេ តនា* ឬដោយចេតនាទន់ខ្សោយ ឬដោយចេតនា បម្រុងធ្វើកម្មដទៃ ប៉ុន្តែ វាប៉ះច្រទ្បំមកលើបុគ្គលដទៃទៅវិញ ឬក៏សេសផល នៃកម្មចាស់រងចាំឱកាសនឹងឲ្យផលហៅថា កដត្តាកម្ម។ បើកម្មទាំង ៣ ខាងដើមមិនមានទេ កដត្តាកម្ម ត្រូវឲ្យផល។

<u>ការគួរសង្កេត</u> ៖ **គរុកម្ម** *មានទម្ងន់ធ្ងន់ណាស់* អាចកាត់ផ្តាច់ឧបនិស្ស័យនៃកម្មចាស់ ចេញបាន។ អាសន្នកម្ម ប្រៀបដូចគោចាស់មានកម្លាំងខ្សោយ ឈរក្បែរទ្វារក្រោល បើគេបើកទ្វារក្រោល ត្រូវតែបានចេញមុនគេ ប៉ុន្តែ បើអាសន្នកម្ម មានកម្លាំងខ្សោយពេក អាចិណ្ណកម្ម ប្រៀបដូចគោមានកម្លាំងមធ្យមនៅឆ្ងាយ

បន្តិចនោះ អាចចេញមកបានមុន អាសន្នកម្មដែរ។ ទោះបីអាសន្នកម្ម ឲ្យផលមុន អាចិណ្ណកម្មក៏ដោយ ក៏មានផលស្រាល និង រយះពេលខ្លីជាងអាចិណ្ណកម្មដែរ។ ឯកដត្តាកម្ម សូម្បីឥតចេតនា ក៏គង់ឲ្យផលដែរ។

## កម្មឱ្យផលតាមលំដាប់ពេលវេលាមាន៤ យ៉ាង

**១-ទិដ្ឋធម្មវេទនីយកម្ម** *កម្មឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ។*

**២-ឧបបជ្ជវេទនីយកម្ម** *កម្មឲ្យផលបន្ទាប់ពីជាតិបច្ចុប្បន្នន គឺក្នុងជាតិទី ២។*

**៣-អបរាបរិយវេទនីយកម្ម** *កម្មឲ្យផលបន្ទាប់ពីជាតិទី ២ គឺរាប់តាំង ពីជាតិទី ៣ រហូតទៅមានឱកាសពេលវេលាណាឲ្យផលពេលនោះ។*

**៤-អហោសិកម្ម** *កម្មដែលមិនឲ្យផល។*

ទិដ្ឋធម្មវេទនីយកម្ម កម្មឲ្យផលក្នុងបច្ចុប្បន្នជាតិនេះ មានទាំងល្អ មានទាំងអាក្រក់ ផ្នែកល្អ ដូចជាអ្នកធ្វើបុ ណ្យកុសល ប្រកបដោយសម្បទា ៤ គឺ **១-ចេតនាសម្បទា** *ការតាំងចិត្តយ៉ាងខ្ជាំងក្លាដាច់ខាត* **២-បច្ចយសម្បទា** *បច្ច័យដែលយកមកធ្វើបុណ្យកុសលនោះស្អាតបរិសុទ្ធ* **៣-វត្ថុសម្បទា** *អ្នកទទួលបច្ច័យនោះ ជាព្រះអរហ ន្ត ឬយ៉ាងទាបត្រឹមអនាគាមី* **៤-គុណាតិរេកសម្បទា** *អ្នកទទួលបច្ច័យនោះ ប្រកប ដោយគុណវិសេស គឺ ទើបនិងចេញពីនិរោធសមាបត្តិ។ ផ្នែកអាក្រក់ ដូចជាអ្នកធ្វើអនន្តរិយកម្មជាដើម។*

*អហោសិកម្ម* កម្មដែលមិនឲ្យផល។ កម្មដែលគេធ្វើដោយឥតចេតនា ឬមានចេតនា ខ្សោយ បើមានកម្មដទៃឲ្យផលហើយ វាក៏ទៅជាអហោសិកម្ម។ កម្មជាអកុសលស្រាលខ្លះ ធ្ងន់ខ្លះ ដូចជាសម្លាប់សត្វផង សម្លាប់មនុស្សផង កាលបើការសម្លា ប់មនុស្សវាឲ្យផលហើយ ការសម្លាប់សត្វវាទៅជាអហោសិកម្ម មិនអាចឲ្យផលក្នុងបដិសន្ធិកាលបានទេ តែវាឲ្យផល ក្នុងបវត្តិកាលបាន។ ចំណែកកម្មជាកុសលស្រាលខ្លះ ធ្ងន់ខ្លះ ក៏មានទំនងដូចគ្នានេះដែរ។ កម្មជាកុសល ប្រកបដោយចេតនា តែមានឥន្ទ្រីយ៍ ៥ គឺ សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ខ្សោយ ហើយមាន តណ្ហា មានៈ ទិដ្ឋិ ខ្លាំង បើមានកម្មដទៃឲ្យផលហើយ វាក៏ទៅជាអហោសិកម្មដែរ។ បុគ្គលធ្វើកម្មជាអកុសល បើមានការភ្ជាក់រឭកប្រកប ដោយធម៌ ៥ គឺ **បុព្វេកតបុញ្ញតា** ការបានសាងបុណ្យទុកក្នុងកាលមុន ***បដិរូបទេសវាស*** ការនៅក្នុងប្រទេសប្រកបដោយសីលធម៌ ***សប្បុរិសូបនិស្សយ*** ការបានសេពគប់នឹងសប្បុ រស ***សទ្ធម្មស្សវន*** ការបានស្តាប់ព្រះសទ្ធម្ម **អត្តសម្មាបណិធិ** ការតាំងខ្លួនទុកដោយប្រពៃ ក៏អាចញ៉ាំងកម្មជាអកុសលនោះ ឲ្យទៅជាអហោសិកម្មបានដែរ។ កម្មរបស់បុគ្គលអ្នកបាន សម្រេចព្រះនិព្វានមិនមានបុគ្គលណាត្រូវទទួលផលនៃកម្មនោះតទៅទៀតហៅថា *អហោសិកម្ម* ។

## កម្មមិនបាត់បង់ទៅណាទេ

ច្បាប់ របស់កម្ម ជាច្បាប់មួយមានលក្ខណៈស្មុគ្រស្មាញពិបាកយល់ឲ្យបានច្បាស់ណាស់ មិនមែនជាវិស័យរបស់យើងទេ ប៉ុន្តែ យើងត្រូវតែខំសិក្សាឲ្យបានយល់ខ្លះ ដើម្បីងាយស្រួលដល់ការបដិបត្តិ។ កម្មមិនមែនគេធ្វើថ្ងៃហ្នឹង ទទួលផលក្នុងថ្ងៃហ្នឹង ទាំងអស់ទេ គេទទួលផលថ្ងៃហ្នឹងផង ថ្ងៃតៗទៅផង ដូចជាដើមស្វាយអីចឹង មិនឲ្យផលតែ ម្តងទាំងអស់ទេ ត្រូវឲ្យផលតៗទៅទៀតផង។ កម្មមិនមែនជាកម្មណាគេធ្វើមុន ត្រូវឲ្យផល មុន កម្មណាគេធ្វើក្រោយ ត្រូវឲ្យផលក្រោយទេ រុក្ខជាតិនោះឲ្យផលមុនគេដាំរុក្ខជាតិណាក្រោយ រុក្ខជាតិនោះឲ្យផលក្រោយ ដូចនោះទេ ត្រូវអាស្រ័យអាកាសធាតុជាដើមរួមផ្សំ ទៀតផង។ កម្មមិនមែនគេធ្វើក្នុងបច្ចុប្បន្ន ជាតិនេះ ហើយទទួលផលក្នុងជាតិនេះទាំងអស់ទេ ត្រូវទទួលជាតិតៗទៅមុខទៀតផង។ រឿងកម្ម វែងឆ្ងាយដូចនេះហើយបានជាធ្វើឲ្យបញ្ញាខ្លី របស់យើងពិបាកយល់។

ក្នុងមហាកម្មវិភង្គសូត្រ ព្រះពុទ្ធសម្តែងប្រាប់អានន្ទថា អ្នកខ្លះធ្វើទុច្ចរិត លុះស្លាប់ទៅ ទៅកើតក្នុ ង អបាយភូមិ អ្នកខ្លះធ្វើទុច្ចរិតដែរ តែលុះស្លាប់ទៅ ទៅកើតក្នុងស្ថានសួគ៌ អ្នកខ្លះ ធ្វើសុចរិតដែរ តែលុះស្លាប់ទៅ ទៅកើតក្នុងអបាយភូមិ[៦]។ ហេតុអ្វីក៏ដូចនេះ? ព្រោះកម្ម មានច្រើនប្រភេទ មានច្រើនស្រទាប់ មានលក្ខខណ្ឌច្រើនណាស់...អ្នកមិនយល់ច្បាស់ អាចភាន់ច្រឡំថា ធ្វើបាបមិនបានបាប ធ្វើបុណ្យមិនបានបុណ្យ។

សព្វថ្ងៃនេះ ក៏នៅមានអ្នកភាន់ច្រឡំដូចនេះដែរ គេតែងសួរគ្នាថា បុណ្យបាប ទៅណាអស់ទៅ មិនឃើញឲ្យផល? គេខំធ្វើបុណ្យច្រើនសន្ធឹក ប៉ុន្តែ មិនឃើញបុណ្យឲ្យ ផល គេបានទទួលតែសេចក្តីទុក្ខលំបាកព្រាត់ប្រាស់ ឪពុក ម្តាយ ប្តី ប្រពន្ធ...។ សូមជម្រាបថា បុណ្យ បាប មិនបាត់បង់ទៅណាទេ សូម្បីផ្លាក់ទឹកក៏មិនរលាយរលេះ ធ្លាក់ ទៅក្នុងភ្លើងក៏មិនឆេះ វារងចាំឲ្យផលដល់យើងជាដរាប ប៉ុន្តែ វាមិនទាន់មានឱកាសល្អនឹងឲ្យផលបាននៅឡើយ។ បុណ្យបាប ដែលនឹងអាចឲ្យផលបានស្រួល ត្រូវអាស្រ័យ ដោយសម្បត្តិ ៤ ឬ វិបត្តិ ៤ ជាអង្គប្រកបផ្សំដែរ បើប្រកបដោយសម្ប ត្តិ ៤ បុណ្យងាយ នឹងឲ្យផល បើប្រកបដោយវិបត្តិ ៤ វិញបុណ្យឲ្យផលពុំសូវបានពេញលេញទេ។

### សម្បត្តិ ៤ យ៉ាង

| | |
|---|---|
| **១-គតិសម្បត្តិ** | *ទីកន្លែងល្អ* |
| **២-ឧបធិសម្បត្តិ** | *រូបរាងកាយល្អ* |
| **៣-កាលសម្បត្តិ** | *ពេលវេលាល្អ* |
| **៤-បយោគសម្បត្តិ** | *ការប្រកប ឬ ធ្វើការល្អ* |

វិបត្តិ ៤ គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងសម្បត្តិ ៤ នេះចុះ គឺ **គតិវិបត្តិ**...។

---

[៦] *សុត្តន្តបិដក មជ្ឈិមនិកាយឧបរិបណ្ណាសក២៨។*

**ឧទាហរណ៍**

**គតិវិបត្តិ** ៖ នាយ ក មានសតិបញ្ញា តែទៅកើតក្នុងទីកន្លែងមិនល្អ ម្ល៉ោះ ហើយ អត់បានទៅជាអ្នកប្រាជ្ញអីធំដុំទេ គ្រាន់តែបានល្មមៗ។ នាយ ក បានធ្វើបុណ្យកុសលទុក ច្រើន ប៉ុន្តែ ពេលដែលព្រះពុទ្ធបានត្រាស់ អាសន្នកម្ម បាននាំនាយ ក ទៅក្នុងអបាយភូមិ ម្ល៉ោះហើយអត់មានឱកាសបានសម្រេចធម៌អ្វីទេ។

**ឧបធិវិបត្តិ** ៖ នាយ ក និង នាយ ខ មានចំណេះវិជ្ជាដូចគ្នា មានចរិយាប្រហែលគ្នា ប៉ុន្តែ នាយ ក មានរាងកាយមាំមួន នាយ ខ មានរោគាព្យាធិច្រើន ដល់ពេលគេជ្រើសរើស យកមនុស្សធ្វើការ គេអត់យកនាយ ក គេមិនយកនាយ ខ ទេ ព្រោះឧបធិ វិបត្តិ ។ នាង ក មានចំណេះវិជ្ជាច្រើន ជាងនាង ខ ប៉ុន្តែ នាង ខ មានរូបរាងទ្រង់ទ្រាយល្អជាងនាង ក ដល់ពេលគេជ្រើសរើសយកមនុស្សធ្វើការផ្នែកទទួលភ្ញៀវ គេយកនាង ខ គេមិនយកនាង ក ទេ ព្រោះឧបធិវិបត្តិ។

**កាលវិបត្តិ** ៖ នាយ ក មិនសូវមានចំណេះវិជ្ជាប៉ុន្មានទេ តែជាអ្នកក្លាហានអ្នកតស៊ូ ចំណែក នាយ ខ មានចំណេះវិជ្ជាច្រើន តែជាមនុស្សមិនហ៊ានតស៊ូ ពេលនោះជាពេលស្រុក ទេសកើតសង្គ្រាម គេត្រូវការយកមនុស្សធ្វើការ គេសម្រេចយក នាយ ក ព្រោះពេលនោះគេត្រូវការតែមនុស្សក្លាហាន។ ឯអ្នកចេះដឹងច្រើនហើយមិនក្លាហាន ក៏ខកខានទៅ ព្រោះកាលវេលាមិនអំណោយ។

**បយោគវិបត្តិ** ៖ នាយ ក មានសតិបញ្ញា និងចំណេះវិជ្ជាច្រើន តែគេមិនបានយក ទៅប្រើការក្នុងផ្លូវសុចរិតទេ គេធ្វើតែរឿងខុសច្បាប់រឿងទុច្ចរិត ម្ល៉ោះហើយក៏ធ្លាក់ខ្លួន មានទោសជាប់គុកជាប់ច្រវ៉ាក់ ខានបានទទួលប្រយោជន៍ពីចំណេះវិជ្ជាទៅ ព្រោះ បយោគវិបត្តិ។

## កម្មជារបស់បុគ្គលម្នាក់ៗ ឬ ?

កម្ម ឬ អំពើដែលបុគ្គលណាមួយ បានធ្វើហើយ ជារឿងរបស់បុគ្គលនោះម្នាក់ៗ កម្មស្សកោម្ហិ កម្មជារបស់ខ្លួន...។ នរណាធ្វើស្រែ នរនោះបានស្រូវ នរណាទទួលទាន នរនោះបានឆ្អែត នរណារៀន នរនោះចេះ នរណាធ្វើទាន រក្សាសីល នរនោះ ទៅស្ថានសួគ៌ នរណាសម្រេចព្រះនិព្វាន នរនោះផុតទុក្ខ ... មិនមែនប្តីធ្វើបុណ្យបានផលដល់ប្រពន្ធផងទេ ឧទាហរណ៍ មឃមាណព បានធ្វើផ្លូវ ធ្វើសាលាសំណាក់និងប្រពន្ធ៣ នាក់ទៀត គឺ នាងសុធម្មា សុនន្ទា សុចិត្តា បានរួមចំណែកធ្វើកិច្ចការបុណ្យកុសលដែរ លុះស្លាប់ទៅ បានទៅកើតក្នុងស្ថានតាវតិង្សរៀងៗខ្លួន។ ចំណែកឯប្រពន្ធមួយទៀតគឺនាងសុជាតា មិនបានរួមធ្វើបុណ្យកុសល អ្វីទេ ដោយគិតថា ប្តីខ្លួនធ្វើហើយ ខ្លួនជាប្រពន្ធមុខជាបានផល បុណ្យដែរ ម្ល៉ោះហើយគិតពីតុបតែងខ្លួន ឲ្យប្តីស្រឡាញ់ជាងគេ លុះស្លាប់ទៅ ស្រាប់តែទៅ កើតជាសត្វកុក...។

រឿងកម្មផលនេះ ព្រះទសពលសម្តែងទុកថា ៖

*អត្តនាវ កតំ បាបំ អត្តនា សង្កិលិស្សតិ*
*អត្តនា អកតំ បាបំ អត្តនាវ វិសុជ្ឈតិ*
*សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ។*
*អ្នកណាធ្វើបាប អ្នកនោះសៅហ្មង*

*អ្នកណាមិនធ្វើបាប អ្នកនោះបរិសុទ្ធ*
*សេចក្ដីបរិសុទ្ធចំពោះខ្លួនម្នាក់ៗ អ្នកដទៃ*
*មិនអាចជម្រះអ្នកដទៃពីខ្លួនឲ្យបរិសុទ្ធបានទេ[៧]។*

៣ក្យថា កម្មជារបស់បុគ្គលម្នាក់ៗ មាននំយជា ២ គឺ ៖

១-បុគ្គលណាធ្វើអំពើអា ក្រក់ ចិត្តរបស់បុគ្គលនោះសៅហ្មង បុគ្គលណាធ្វើអំពើល្អ ចិត្តរបស់បុគ្គលនោះបរិ សុទ្ធ។ អ្នកដទៃ មិនអាចធ្វើចិត្តនៃបុគ្គលនោះឲ្យសៅហ្មងឬបរិសុទ្ធ បានទេ តែគេអាចធ្វើរឿងខាងក្រៅខ្មៅឲ្យទៅជាស ល្អឲ្យទៅជាអាក្រក់បាន។

២-ផលនៃបាបបុណ្យ ពិតប្រាកដត្រូវបានទៅអ្នកធ្វើ អ្នកឯទៀតបានទទួលត្រឹ មតែ ចំណែកឬចំហាយបាបឬបុណ្យតែប៉ុណ្ណោះ។ ចំហាយនៃបាបឬបុណ្យនេះ ក៏មិនមែនជា រឿងអីស្រាលប៉ុន្មានទេ យើងត្រូវតែសិក្សា។

ឧទាហរណ៍ ឪពុកម្ដាយធ្វើល្អ គេរាប់អានតដល់កូន ឪពុកម្ដាយធ្វើអាក្រក់ គេអាច ធ្វើបាបកូនជំនួសព្រោះការឲ្យផលរបៀបនេះ ក៏អាចញ៉ាំង ឪពុកម្ដាយឲ្យកើតទុក្ខមិនស្មើ ទេ។ សុមង្គលសេដ្ឋី និយាយពាក្យសម្ដីមិនល្អតែមួយម៉ាត់ ចោរវា ... លួចកាប់ជើងគោ របស់គាត់ រហូតដល់ទៅដុតគន្ធកុដិ ដែលគាត់បានសាងថ្វាយព្រះពុទ្ធកស្សបទៀត គោវាអត់ដឹងអីទេ គន្ធកុដិវាឥតមានវិញ្ញាណទេ តែក៏ត្រូវបានទទួលផលដែរ នេះជាការឲ្យ ផលជំនួស ឬជាការជួសជុល ជាផលនៃកម្មមួយបែប ដែលយើងត្រូវតែសិក្សា។ ប៉ុល ពត ប្រល័យពូជសាសន៍ ឯង ដោយសារកម្មរបស់វា ជនបរទេសស្អប់ខ្ពើម ដល់ខ្មែរឯទៀតផង ដែរ ឬឧបមាថា បើនាយករដ្ឋមន្ត្រីខ្មែរណាម្នាក់ កាត់ទឹកដីឲ្យបរទេស ខ្មែរឯទៀតក៏ត្រូវ ទទួលទុក្ខវេទនា ដោយសារអំពើនោះផងដែរ។ ដូចនេះដើម្បីឲ្យយល់ច្បាស់រឿងកម្មនេះ ថែមទៀត យើងគួរចែកកម្រិតកម្មផ្សេងៗ ដូចតទៅនេះ ៖

១-កម្មរបស់បុគ្គល

២-កម្មរបស់គ្រួសារ

៣-កម្មរបស់ពួកគណៈ ឬសង្គម

៤-កម្មរបស់ជាតិ

៥-កម្មរបស់ពិភពលោក

កម្មរបស់បុគ្គល គឺថា បុគ្គលណារក បុគ្គលនោះបាន បុគ្គលណារៀន បុគ្គលនោះ ចេះ... ប៉ុន្តែ បើកម្មនោះមានកម្រិតដល់គ្រួសារផង បុគ្គលអ្នករៀនចេះនោះ អាចយក ចំណេះ ដែលខ្លួនចេះ ទៅប្រើជា ប្រយោជន៍ដល់គ្រួសារបានផង បើកម្មនោះមានកម្រិតដល់ ពួកគណៈ ឬសង្គម អាចបានជាប្រយោជន៍ ដល់ពួកគណៈឬដល់សង្គមផង បើកម្មនោះមាន កម្រិតដល់ថ្នាក់ជាតិ អាចទៅជាប្រយោជន៍ ដល់ជាតិបានផង បើកម្មនោះមានកម្រិតដល់ ពិភពលោក អាចទៅជាប្រយោជន៍ដល់ពិភពលោកផងទៀត។កម្មរបស់បុគ្គលអាច

[៧] *សុត្តន្តបិដក ខុទ្ទកនិកាយខុទ្ទកបាឋទិ ៥២/២២/៥៦។*

តំណាងឲ្យបុគ្គលផង ឲ្យគ្រួសារផង ឲ្យពួកគណៈ ឬឲ្យសង្គមផង ឲ្យប្រទេសជាតិ មាតុភូមិផង រហូតដល់ជាតំណាងឲ្យពិភពលោកផងដែរ ស្រេចហើយតែទំហំ និងកម្រិត នៃកម្មនោះៗ ។

ម៉្យាងទៀត សមូហកម្ម កម្មរួម គឺធ្វើរួមគ្នា ឧទាហរណ៍ ឈ្មួញទុច្ចរិត យកប្រាក់ទៅសូកប៉ាន់មន្ត្រី ពុករលួយៗ ទទួលយកប្រាក់សំណូកនោះជាប្រយោជន៍ផ្ទាល់ ខ្លួន... ពួកតំណាងរាស្ត្រ ដឹងថាមន្ត្រីរដ្ឋាភិបាលពុករលួយតែមិនសាកសួរដេញដោលរក ខុសត្រូវតាមផ្លូវច្បាប់ សុខចិត្តក្បត់មុខងាររបស់ខ្លួន ព្រះរាជា ជាព្រះបិតារបស់រាស្ត្រ មិនដោះស្រាយ មិនបានបំពេញព្រះរាជករណីយកិច្ចឲ្យបានត្រឹ មត្រូវ ដើម្បីជួយរាស្ត្រ ឯរាស្ត្រទៀតសោត ក៏មិនតវ៉ា មិនហ៊ានធ្វើបាតុកម្ម ឬពួនសម្ងំយកសុខដោយគំនិតខុស អ្នកទាំងអស់នោះ ឈ្មោះថាធ្វើសមូហកម្ម កម្មរួម ។ ហេតុនេះ ត្រូវតែទទួលផលកម្មទាំង អស់គ្នា ធ្ងន់ឬស្រាល តាមកម្រិតនៃការចូលរួមនឹងប្រកែកថាខ្លួនមិនខុសមិនបានទេ ព្រោះការមិនបា នធ្វើនោះហើយ គេចាត់ទុកជាការធ្វើខុសមួយបែបដែរ ដោយមិនបានធ្វើឲ្យត្រឹម ត្រូវតាមនាទីរបស់ខ្លួន។ ដូចនេះ បុគ្គលម្នាក់ៗ ត្រូវគិតថា អញបានធ្វើអ្វីហើយ អញមិនទាន់បានធ្វើអ្វី អញបានធ្វើខុស ឬត្រូវ កម្មនោះឲ្យជាផល វិបាកដល់អាត្មាអញតែម្នាក់ឯង ឬដល់គ្រួសារ ដល់ពួកគណៈ ដល់សង្គម ដល់ប្រទេសជាតិ ឬដល់ពិភពលោក ផងដែរ មុននឹងធ្វើអ្វីៗ ត្រូវគិតពិចារណាឲ្យម៉ត់ចត់សិនសឹមធ្វើ ទើបជាការប្រពៃ។

## វិធីលាងបាប

ក្នុងសាសនាព្រាហ្មណ៍ គេមានវិធីលាងបាប ដោយចុះទៅមុជទឹកក្នុងទន្លេគង្គា គេជឿថាទន្លេគង្គាជាទន្លេសក្តិសិទ្ធិ បើនរណាបានមុជទឹកបន្សាត់បាបក្នុងទន្លេគង្គា បាប របស់អ្នកនោះ នឹងជ្រះអស់រលីង។ សាសនាឯទៀតខ្លះ គេមានវិធីលាងបាប ដោយគ្រាន់ តែសារភាពប្រាប់កំហុសដែលខ្លួនបានធ្វើកន្លងមកហើយ ព្រះជាម្ចាស់លោកនឹងជួយឲ្យ ជ្រះបាបបាន។ បាបជាកិលេសគ្រឿងសៅហ្មងនៃចិត្ត ចិត្តជានាមធម៌អត់រូបរាង ទាំងកិលេសទាំងចិត្ត សុទ្ធតែអត់រូបរាងដូចគ្នា គេយកទឹកដែលជា រូបធម៌ទៅលាងជម្រះកិលេសនិងចិត្តដែលជានាមធម៌ ដូចជាពិបាកយល់។ ព្រះទសពលសម្តែងថា បើទឹកអាច លាងបាបបានមែន សត្វទឹកដូចជាត្រីអណ្តើកជាដើម វានឹងជ្រះបាបជាងមនុស្ស ហើយមាន ឱកាសទៅកើតទីកន្លែងល្អៗ ក្នុងស្ថានសួគ៌មុនមនុស្សយើងអស់ហើយ។ វិធីសារភាព ប្រាប់ កំហុសដែលខ្លួនបានធ្វើកន្លងមកហើ យ ជាការល្អម៉្យាងដែរ ប៉ុន្តែ បើគ្រាន់តែសារភាព ហើយ មិនកែប្រែការបដិបត្តិឲ្យល្អផងទេ វាអត់មានន័យអ្វីសម្រាប់ការលាងបាបនោះដែរទេ។

ព្រះពុទ្ធសាសនា មិនមានវិធីលាងបាបដូចសាសនាអស់នោះទេ ប៉ុន្តែមានវិធីបដិបត្តិ ធម៌ បដិបត្តិធម៌ឲ្យល្អឲ្យច្រើនឡើងៗបាបកាន់តែតិចទៅៗ ថយទៅៗ ដូចជាអំបិ ល ១ ដុំ ក្នុង ភាជនៈធំ ១ បើគេចាក់ទឹកសាបថែមកាន់តែច្រើនឡើងៗ ជាតិអំបិលកាន់តែសាបទៅៗ អត់ មានន័យអ្វីទៀតទេ។សេចក្តីនេះ មាននៅក្នុងលោណកសូត្រ សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១/៣៦៨។ រឿងកម្ម ១២ យ៉ាង បើគេសិក្សាពិចារណាឲ្យម៉ត់ចត់ គេនឹងឃើញ ថា កម្មចេះជួយគ្នា ចេះបៀតបៀនគ្នា ចេះកាត់ផ្តាច់គ្នា នេះជាវិធីរំលាយបាប ឬលាងបាប ម៉្យាងដែរ។ ក្នុងគម្ពីរ សុត្តន្តបិដក សំយុត្តនិកាយ មហាវារវគ្គ ៣៧/១៣១ ព្រះពុទ្ធអង្គសម្តែង ថា "ម្នាលភិក្ខុទាំងឡាយ ក្អមដែលគេផ្កាប់ចុះ រមែងខ្ជាក់ចោលនូវទឹក មិនស្រូបចូលមកវិញឡើយ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើចំរើននូវមគ្គ ប្រកបដោយអង្គ ៨ ដ៏ប្រសើរ ធ្វើឲ្យច្រើនឡើងៗ នូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ រមែងខ្ជាក់ចោលនូវអកុសលធម៌ ដ៏លាមក ចេញមិនស្រូបចូលវិញឡើយ

ក៏យ៉ាងនោះដែរ។ នេះជាវិធីលាងបាបដែរ។ ក្នុងគម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត អបាយកវគ្គ ៤១/៤២៦ ព្រះពុទ្ធសម្តែងថា អ្នកប្រាជ្ញទាំងឡាយពោល ចំពោះនូវបុគ្គលអ្នកស្អាតកាយ ស្អាតវាចា ស្អាតចិត្ត មិនអាសវៈ ជាអ្នកស្អាត បរិបូណ៌ដោយការ ស្អាត ថាជាបុគ្គលមានបាបលាងជម្រះហើយ។ ក្នុងគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ ខុទ្ទកបាឋទិ ៥២/៥៨ ព្រះពុទ្ធអង្គសម្តែងថា បុគ្គលណា លះចោលនូវបាបកម្មដែលខ្លួនធ្វើហើយ ដោយកុសល បុគ្គលនោះ រមែងញ៉ាំងលោកនេះឲ្យភ្លឺស្វាង ដូចជាព្រះចន្ទចេញផុតពីពពក។

ហេតុនេះ ពួកពុទ្ធបរិស័ទត្រូវយកទៅបដិបត្តិឲ្យបានល្អប្រពៃដូចតទៅនេះ៖

*១-កុំធ្វើបាប កុំសន្សំបាប ។*

*២-បាបចាស់ដែលធ្វើហើយកុំព្រងើយកន្តើយត្រូវលាងចេញ ដោយការខំធ្វើសេចក្តីល្អឲ្យច្រើនឡើងៗ ។*

*៣-កុំស្វែងរក កុំធ្វើពិធីកម្មលាងបាបផ្សេងៗទៀត ក្រៅពុទ្ធសាសនា ព្រោះមិនមែនគ្រាន់តែមិនបានការទេ វានាំឲ្យខូចខាតផលប្រយោជន៍ ខូចខាតពេលវេលា ខូចទាំងគំនិត កើតជាទិដ្ឋិខុស (មិច្ឆាទិដ្ឋិ) ថែមទៀត។*

ក្នុងពុទ្ធសាសនា មិនមានវិធីលាង បាបដូចសាសនាគេ ប៉ុន្តែមានវិធីបដិបត្តិយ៉ាងសក្តិសិទ្ធិ ដូចបានជម្រាបមកហើយ ។

## លទ្ធិអន្យតិរ្ថិយ៍

លទ្ធិអន្យតិរ្ថិយ៍ គឺលទ្ធិសាសនាដទៃ ក្រៅពីពុទ្ធសាសនា។ លទ្ធិអន្យតិរ្ថិយ៍គេមានជំនឿ ៣យ៉ាងដូចតទៅនេះ ៖

*១-បុព្វេកតហេតុ បុរសបុគ្គល ទទួលសេចក្តីសុខក្តី សេចក្តីទុក្ខក្តី មិនសុខ មិនទុក្ខក្តី ទាំងអស់នោះ ព្រោះហេតុតែអំពើដែលគេបានធ្វើហើយក្នុងកាលមុន ។*

*២-ឥស្សរនិម្មានហេតុ បុរសបុគ្គល ទទួលសេចក្តីសុខក្តី សេចក្តីទុក្ខក្តី មិនសុខមិនទុក្ខក្តី ទាំងអស់នោះ ព្រោះហេតុតែទេវតាដ៏ជាធំបណ្តាលឲ្យ ។*

*៣-អហេតុអប្បច្ចយា បុរសបុគ្គល ទទួលសេចក្តីសុខក្តី សេចក្តី ទុក្ខក្តី មិនសុខមិនទុកក្តី ទាំងអស់នោះ ព្រោះមិនមានហេតុ មិនមានបច្ច័យ ៨។*

លទ្ធិទី ១ បុព្វេកតហេតុ ... ជឿទៅលើកម្មចាស់ ។ លទ្ធិនេះ បើគេមើលសើៗ ស្រដៀងគ្នានិងពុទ្ធសាសនាដែរ ព្រោះពុទ្ធសាសនាមាន បុព្វេកតបុញ្ញតា ការបានធ្វើបុណ្យទុកកាលពីជាតិ មុន... ។ ប៉ុន្តែបើគេពិនិត្យ ឲ្យស៊ីជម្រៅឃើញខុសគ្នាស្រឡះ ព្រោះលទ្ធិអន្យតិរ្ថិយ៍ ប្រកាន់មាំថា អ្វីៗ ទាំងអស់នោះសុទ្ធតែកើតមកពីផលនៃកម្មចាស់ កម្មចាស់កំណត់ទុកស្រេចហើយ មិនអាច កែបាន ជាពួកអកិរិយវាទ ធ្វើឲ្យមនុស្សអស់ឆន្ទៈ និងវិរិយៈជាដើម ម្លោះហើយគ្មានចំណង់ គ្មាន ការប្រឹងប្រែងកសាង ឬរើបម្រះអ្វីទាំងអស់

---

[៨] *សុត្តន្តបិដកអង្គុត្តរនិកាយតិកនិបាត២១/១៧៩។*

។ ឯពុទ្ធសាសនា មានរឿងកម្មចាស់ដែរ តែមិនប្រកាន់ មាំថា អ្វីៗ ទាំងអស់នោះ សុទ្ធតែជាផលនៃកម្មចាស់ទេ កម្មចាស់មិនអាចកំណត់ទុកទាំងស្រុង ដោយមិនឲ្យមានការកែប្រែអ្វីបានសោះទេ ។ ពាក្យប្រៀនប្រដៅរបស់ព្រះអង្គជាកិរិយវាទ ដឹកនាំ ឲ្យមានឆន្ទះ វិរិយៈ ខំកែលំអ កសាងខ្លួន រំដោះខ្លួនដោយខ្លួនឯង ។ ព្រះអង្គសម្ដែងថា សុខ ទុក្ខ មិនមែនសុទ្ធតែជាផលនៃកម្មចាស់ទាំងអស់នោះទេ ឧទាហរណ៍ ពេលណាគេខំប្រឹងប្រែង ប្រើ កម្លាំងហួស ពេលនោះ គេមានទុក្ខវេទនាខ្លាំង ពេលណាគេឈប់ប្រឹងប្រែង ពេលនោះទុក្ខវេទនា ក៏រលត់ ។ ពេលណាគេជាប់ចិត្តនិងស្ត្រីម្នាក់ ហើយស្ត្រីនោះទៅទាក់ទងនឹងបុរសដទៃ ពេលនោះ គេកើតទុក្ខ ពេលណាគេឈប់ជាប់ចិត្តនឹងបុរសដទៃ ពេលនោះគេក៏មិនកើតទុក្ខដែរ ។ ម៉្យាងទៀត ក្នុងពេលដែលសុភមាណពទូលសួរថា អ្វីជាហេតុ បច្ច័យធ្វើឲ្យបុគ្គលខ្លះមានអាយុវែង បុគ្គលខ្លះមានអាយុខ្លី ។ នេះជារឿងរបស់កម្មចាស់ ។ ដល់មករឿងកម្មថ្មី ព្រះអង្គសម្ដែងថា ហេតុដែលនាំឲ្យអាយុខ្លីមាន ៥ យ៉ាងគឺៈ

*១-មិនចេះធ្វើខ្លួនឲ្យសប្បាយ*

*២-មិនស្គាល់ប្រមាណក្នុងការសប្បាយ*

*៣-បរិភោគភោជនាហារស្លែងដល់សុខភាព*

*៤-ត្រាច់ចរមិនស្គាល់កាលៈទេសៈ*

*៥-មិនប្រព្រឹត្តព្រហ្មចារ្យ គឺសេពកាមគុណហួសប្រមាណ ។*

បើប្រព្រឹត្តផ្ទុយពីនេះ នឹងទៅជាហេតុដែលនាំឲ្យមានអាយុវែង ។ បើ កម្មចាស់កំណត់ទុកស្រេចហើយចាំបាច់មានកម្មថ្មីនេះធ្វើអ្វីទៀត ?

លទ្ធិទី ២ ឥស្សរនិម្មានហេតុ ... អ្វីៗ ទាំងអស់សុទ្ធតែទេវតាដ៏ជាធំបណ្ដាលឲ្យ ។ លទ្ធិនេះពឹងផ្អែកលើវត្ថុខាងក្រៅលើព្រះជាម្ចាស់ បដិសេធសមត្ថភាពរបស់មនុស្ស ។ បញ្ញាស្មារតីសេចក្ដីព្យាយាមជាដើមត្រូវគាំងអស់ ព្រោះទេវតាដ៏ជាធំ លោកសម្រេចឲ្យទាំងអស់ហើយ ។

លទ្ធិទី ៣ អហេតុអប្បច្ចយា... អ្វីៗ ទាំងអស់មិនមានហេតុ មិនមានបច្ច័យ ។ លទ្ធិនេះ គ្មានអ្វីជាគោលទេ សុខក៏សុខឯង មានក៏មានឯង ក្រក៏ក្រឯង សុទ្ធតែជារឿងចៃដន្យទាំងអស់ មិនចាំបាច់ខំមិនចាំបាច់ប្រឹងប្រែងទេ ដេកចាំយកតែម្ដង ។

លទ្ធិទាំង ៣ នេះ ព្រះសម្មាសម្ពុទ្ធ ចាត់ទុកជាលទ្ធិខុស មិននាំមកនូវ សេចក្ដីសុខ ចំរើនដល់ជាតិនិងសាសនា ឬដល់បុគ្គលណាទេ អ្នកណាបដិបត្តិតាម អ្នកនោះ ឈ្មោះថាជា មនុស្សក្រៅពុទ្ធសាសនា ។

សព្វថ្ងៃនេះ នៅប្រទេសខ្មែរយើងមានអ្នកកាន់ពុទ្ធសាសនាមួយចំនួនកំពុងធ្លាក់ខ្លួនចូលក្នុងលទ្ធិអន្យតិរ្ថិយ៍ គេនិយាយតែពីកម្មចាស់ ពីឧបនិស្ស័យ ពីហេតុបច្ច័យ គេអត់គិតរឿងកម្មថ្មី អត់គិតរឿងអប់រំអីទេ ។ បើឃើញក្មេងធ្វើអំពើបាបដូចជាចាប់ចង្រិតបញ្ជល់គ្នា គេថាកុំហាមឃាត់ ក្មេង ព្រោះជាកម្មរបស់សត្វចង្រិតទេ បើឃើញកូនធ្វើខុសកុំស្ដីបន្ទោសវា ស្រេចតែឧបនិស្ស័យ របស់វាចុះ ។ បើរឿងយាយ ត្រូវវាយជេរថៅ និយាយថា បើកុំតែវាយ កុំតែជេរវាស្រួលសោះ គេនិយាយថា វាមិនអាចវាយ កុំជេរអីចឹងបានទេ ព្រោះហេតុបច្ច័យត្រូវតែអីចឹង ។ បើបដិសេធ កម្មថ្មី បដិសេធការអប់រំ ក្រសួងអប់រំជាតិដូចជាអស់កិច្ចការ គម្រោងការរបស់រដ្ឋាភិបាល នឹង កសាងអភិវឌ្ឍន៍ប្រជាជន ឬយុវជន ក៏ធ្វើទៅមិនបានកា រ ព្រោះកម្មចាស់គេកំណត់អស់ហើយ ឧបនិស្ស័យគេមានរៀងៗខ្លួនហើយ ព្រះពុទ្ធក៏មិនចាំបាច់ប្រៀនប្រដៅគេដែរ

ពាក្យថា កុំសេពគប់ និងមនុស្សពាល ចូរសេពគប់បណ្ឌិត ពាក្យថា ចូរលះបង់អកុសល ចូរចំរើននូវកុសលជាដើម អត់មានន័យតទៅទៀតទេ អាចលប់ចោលបានហើយមើលទៅ ?

ប្រទេសជិតខាង សៀម យួន ជាដើម គេកំពុងតែកសាងប្រទេសជាតិ កំពុងតែអប់រំ ប្រជាជនគេឲ្យចំរើនជឿនលឿនតទៅទៀត កំពុងតែរកផ្សាលក់អីវ៉ាន់ថែមទៀត គេឃើញខ្មែរ យើងមួយចំនួន បដិបត្តិធម៌ងងិតងងុល របៀបហ្នឹង រហូតដល់ខ្មែរយើងទិញបន្លែគេយកមកស៊ី ហើយ គេសើចផង គេញញឹមផង ព្រោះក្តោងរបស់គេកាន់តែត្រូវខ្យល់ហើយ...។

សូមអ្នកដឹកនាំជា តិសាសនាយើង មេត្តាជួយពិនិត្យមើលធម៌អាថ៌ និងជួយផ្សព្វផ្សាយ ធម៌អាថ៌ឲ្យបានត្រឹមត្រូវផង ប្រយ័ត្នងាប់អត់អំបិលប្រឡាក់ ។

## និយាម ៥

ការប្រព្រឹត្តទៅ ការកំណត់ ច្បាប់ ក្រឹត្យក្រមរបស់ធម្មជាតិ ហៅថា និយាម មាន ៥ យ៉ាងគឺ ៖

*១-**ឧតុនិយាម** ច្បាប់របស់រដូវ មានក្តៅ មានត្រជាក់ ខ្យល់ ភ្លៀង... ធ្វើឲ្យមានការប្រែស្រួល ផ្សេងៗ ពេលក្តៅធ្វើឲ្យមានបេញញើស ពេលត្រជាក់ខ្លាំង ធ្វើឲ្យទឹកកកជាដើម នេះហៅថា ឧតុនិយាម ។*

*២-**ពីជនិយាម** ច្បាប់របស់ពូជពន្ធុ៍ ពូជកុលាបដើមវាមានបន្លា ពូជចំប៉ាដើមវាមានរលីង ពូជព្រីងផ្លែវាខ្មៅ ពូជអំពៅដើមវាផ្អែម... ពូជមនុស្ស ពូជសត្វមានប្រភេទប្លែកៗផ្សេងៗគ្នានេះជា ពីជនិយាម ។*

*៣-**ចិត្តនិយាម** ច្បាប់របស់ចិត្ត ចិត្តកើតឡើងទទួលអារម្មណ៍ តើមានច្បាប់យ៉ាងម៉េច គឺមានអារម្មណ៍មកប៉ះធ្វើឲ្យកើតជាភវង្គចលនៈ ភវង្គុបច្ឆេទៈ ។ល។ រហូតដល់ទទួលដឹងសោយអារម្មណ៍ហើយ ក៏ធ្លាក់ចុះកាន់ភវង្គវិញ ។ ចិត្តដួងនេះកើតឡើង តើមានចេតសិកអ្វីកើតជាមួយខ្លះ? ចេតសិកដួងនេះកើតហើយ តើមានចេតសិកណា អាចកើតជាមួយគ្នាបាន ? ចេតសិកណា កើតមិនបាន ដូចនេះជាដើម ហៅថា ចិត្តនិយាម ។*

*៤-**កម្មនិយាម** ច្បាប់របស់កម្មគឺកំណត់តាមហេតុផល បើមានហេតុ ត្រូវតែមានផល កម្មជាហេតុ ត្រូវតែមានវិបាកគឺផល ដូចនេះអំពើល្អ ឬអំពើអាក្រក់ តែងតែមានផលជាដរាប ការបានទទួលល្អ មិនមែនព្រោះបុគ្គលណា ឬព្រះជា ម្ចាស់ណាឲ្យរង្វាន់ទេ ឯការទទួលផលអាក្រក់ ក៏មិនមែនព្រោះបុគ្គលណាឬព្រោះអាទិទេពដាក់ទោសដែរ នេះជាច្បាប់របស់កម្ម កម្មនិយាម ។*

*៥-**ធម្មនិយាម** ច្បាប់របស់ធម្មជាតិ គឺអ្វីៗដែលផ្សំគ្នាកើតឡើងហើយ មិនអាចមានសភាព នៅដដែលបាន ត្រូវតែប្រែប្រួ ល និងមានការរលត់សាបសូន្យទៅវិញ*

*ក្នុងទីបំផុតជាមិនខាន គ្រាន់តែយូរឬឆាប់ទៅតាមហេតុបច្ច័យ គឺគ្រឿងផ្សំ។ មនុស្សជាសង្ខារ គឺរបស់ផ្សំ ដូចនេះត្រូវតែ មានចាស់ ឈឺ ស្លាប់ ដែលគេនិយាយភាសាធម៌ថា អនិច្ចំ ទុក្ខំ អនត្តា នេះជាធម្មនិយាម ។*

និយាមទាំង៥នេះ ជាច្បាប់ធម្មជាតិ ប្រព្រឹត្តទៅ តាមច្បាប់របស់ខ្លួន អតមាននៅក្រោម អំណាច ឬឥទ្ធិពលរបស់បុគ្គលណាទេ ។ រឿងកម្ម ជានិយាមមួយក្នុងចំណោមនិយាមទាំង ៥តែ ប៉ុណ្ណោះ។ សូមសង្កេតមើល ឧទាហរណ៍ តទៅនេះ នាយ ក បែកញើស តើមានពីហេតុអ្វី ? បើមកពីអាកាសក្តៅ នេះជាឧតុនិយាម បើមកពីធ្វើខុសហើយភ័យខ្លួន នេះជាកម្មនិយាម។ នាង ខ ចេញទឹកភ្នែក តើមានមកពីហេតុអ្វី បើមកពីអរពេក នេះជាចិត្តនិយាម បើមកពីផ្សែងចូល ភ្នែក នេះជាឧតុនិយាម ។ ហេតុនេះ យើងមិនត្រូវយោលអ្វីៗទាំងអស់ឲ្យទៅជារឿងរបស់កម្មនោះ ទេ ត្រូវតែសិក្សា និងពិចារណាឲ្យម៉ត់ចត់សិន សឹមសម្រេចទើបទុកជាការត្រឹមត្រូវ ។

ព្រះពុទ្ធសម្តែងថា អ្នកណាជឿថា រោគាព្យាធិទាំងអស់សុទ្ធតែកើតមកពីកម្ម ជំនឿបែប នេះជាជំនឿខុស ព្រោះថារោគាព្យាធិខ្លះ កើតមកពីមិនចេះថែរក្សាខ្លួនក៏មាន រោគាព្យាធិខ្លះ កើតមកពីរដូវក៏មាន រោគាព្យាធិខ្លះ កើតមកពីប្រមាត់ ស្លេស្មបណ្តាលក៏មាន រោគាព្យាធិខ្លះ កើតមកពីកម្មក៏មាន -ល- ។ ដូចនេះអ្នកណានៅតែជឿថា អ្វីៗទាំងអស់សុទ្ធតែជាផលនៃកម្ម អ្នកនោះ ឈ្មោះថាជាមនុស្សក្រៅពុទ្ធសាសនា ។

## ទស្សនគតិចំពោះកម្ម

សាសនាព្រាហ្មណ៍ មានរឿងកម្មដែរ តែកម្មរបស់គេគាំទ្រការបែងចែកមនុស្សឲ្យមាន វណ្ណៈ គេនៅមានអត្តា ។ សាសនាជេន (និគ្រន្ថ) ក៏មានកម្មដែរ តែកម្មរបស់គេងាកមកខំរំលត់កម្មចាស់ ដោយ បំពេញតបៈ ហើយមិនមានការកសាងកម្មថ្មីអ្វីទៀតទេ ។

ចំណែកកម្មក្នុងពុទ្ធសាសនារបស់យើង មិនដូចកម្មរបស់ពួកអ្នកអស់នោះទេ មិនមានការ បែងចែកមនុស្សវណ្ណៈថ្នាក់ជាន់ទេ មិនមានអត្តាទេ ជាអនត្តា។ ដើម្បីនិងបន្ថយ ឬរំលត់ផលនៃ កម្មចាស់ មិនប្រើវិធីបំពេញតបៈទេ តែត្រូវជម្រុញឲ្យខំកសាងកម្មថ្មីៗ ឲ្យច្រើនឡើងៗ ថែមទៀត។ ហេតុនេះ អ្នកកាន់ពុទ្ធសាសនា ត្រូវសិក្សារឿងកម្ម ត្រូវបដិបត្តិឲ្យត្រូវតាមច្បាប់របស់កម្មដែល ព្រះពុទ្ធសម្តែងទុក ត្រូវមានទស្សនគតិចំពោះកម្មឲ្យបានត្រឹមត្រូវ ។ ក្នុងទីនេះនឹងនិយាមចំពោះ ទស្សនគតិ គឺ ដំណើរនៃការយល់ឃើញ តើការយល់ឃើញរបស់ពុទ្ធសាសនិកជនយើង ចំពោះ កម្មបានត្រឹមត្រូវហើយឬនៅ? ខ្ញុំយល់ឃើញថា ពុទ្ធសាសនិកជនយើង នៅមានទស្សនគតិ ល្អៀងឃ្លៀងឃ្លាតច្រើននៅឡើយ ។

ទស្សនគតិ មាន ២ យ៉ាងគឺ ៖ ១-ទស្សនគតិចំពោះខ្លួនឯង ២-ទស្សនគតិចំពោះអ្នកដទៃ ។ ទស្សនគតិ ចំពោះខ្លួនឯង ឧទាហរណ៍ យើងកើតមកក្នុងត្រកូលក្រីក្រ ឬកើតមកពិកា តើយើង មានទស្សនគតិដូចម្តេ ច ? យើងបន្ទោសព្រះព្រហ្ម ឬបន្ទោសសង្គម ឬក៏បន្ទោឪពុកម្តាយ ?

ព្រះព្រហ្មគ្មាននរណាមួយដែលជួបទេ ព្រះពុទ្ធត្រាស់សួរពួកព្រាហ្មណ៍ថា ឪពុកម្តាយ អ្នកឯងដែលជួប ព្រះព្រហ្មឬទេ ? ព្រាហ្មណ៍តបថា មិនដែលជួបទេ ព្រះអង្គ ព្រះពុទ្ធសួរទៀតថា ចុះជីតាអ្នកឯងដែលជួប ព្រះព្រហ្មឬទេ ? ព្រាហ្មណ៍ឆ្លើយថា មិនដែលជួបទេ ព្រះអង្គ ព្រះពុទ្ធសួរ តទៅទៀតថា ចុះជីតារបស់ជីតាអ្នកឯង ដែលជួបព្រះព្រហ្មឬទេ ? ព្រាហ្មណ៍ឆ្លើយថា ទេ ទេរហូត ដូចនេះ គឺគ្មាននរណាដែលជួបព្រះព្រហ្មទេ

តើយើងបន្ទោសយ៉ាងម៉េច ។ របបសង្គមបានកែប្រែ មកជាច្រើន ប៉ុន្តែ សង្គមមិនអាចដោះស្រាយបានគ្រប់បញ្ហា ទេ គឺដោះស្រាយបានខ្លះៗ ប៉ុណ្ណោះ សូម្បីសង្គមកុម្មុយនិស្ត ដែលអួតអាងថាធ្វើមនុស្សឲ្យស្មើភាពគ្នានោះ ក៏ធ្វើមិនកើតដែរ ឥឡូវ ដួលប៉ះដើង ទៅហើយ តើយើងទៅបន្ទោសនរណា ឬបន្ទោសឪពុកម្តាយយើង ឪពុកម្តាយ មិនចង់ឲ្យកូនក្រ មិនចង់ឲ្យកូនពិកា ប៉ុន្តែ គាត់មិនដឹងធ្វើយ៉ាងម៉េចដែរ មិនទាំងដឹងថា កូនណា ប្រុស ឬស្រី មកកើតជាមួយគាត់ផង តើបន្ទោសគាត់យ៉ាងម៉េច ? ការបន្ទោសគេចេះតែបន្ទោស បាន ប៉ុន្តែ គ្មានដោះស្រាយអីបានទេ បានតែក្តៅក្រហាយ ដូចនេះ ត្រូវវិលមកបន្ទោសខ្លួនឯងទើបល្អជាង ។ ត្រង់ចំណុចហ្នឹងដែលយើងត្រូវប្រយ័ត្ន ត្រូវបដិបត្តិឲ្យបានល្អ ។ អ្នកខ្លះគេថា នេះកម្មរបស់យើងហើយ យើងត្រូវអត់ធន់ទ្រាំទទួលទៅ ចប់យោបល់ត្រឹមប៉ុណ្ណោះ ។ ទស្សនគតិនេះ ខុសហើយ ចូលលទ្ធិអន្សត្ថិរិយ៍ហើយ យកជាការមិនបានទេ។ ចុះទស្សនគតិ ត្រូវ តើដូចម្តេច? ឯទស្សនគតិត្រូវដូចនេះគឺ១-ត្រូវទទួលសារភាពថា នេះជាផលនៃអកុសលកម្មចាស់របស់យើង វាជាមេរៀនមួយដ៏ល្អសម្រាប់យើង យើងត្រូវតែទទួលផលនោះ២-មេរៀននៃកម្មចាស់ខុស យើងមានហើយ យើងមិនត្រូវធ្វើអំពើខុសតទៅទៀតទេ តែយើងក៏មិនត្រូវនៅស្ងៀម ចាំទទួលផលនៃកម្មចាស់នោះទាំងស្រុងទេ យើងត្រូវខំធ្វើសេចក្តីល្អ ដើម្បីកែប្រែផលនៃ កម្មចាស់នោះ ឲ្យធូរស្រាលមកវិញ ដូចជាយើងកើតក្នុងត្រកូលក្រីក្រ បើយើងខំប្រឹង វានឹងធូរស្រាលបានខ្លះដែរ មិនមែនកែមិនបានសោះនោះទេ ។ ទស្សនគតិ ចំពោះអ្នកដទៃ ឧទាហរណ៍ យើងឃើញគេមានសេចក្តីទុក្ខលំបាក យើងមានទស្សនគតិថា នេះជាកម្មរបស់គេ គេត្រូវតែទទួលផលបែបហ្នឹង យើងត្រូវតាំងចិត្តជាឧបេក្ខា គឺព្រងើយកន្តើយទៅមុខឲ្យគេទទួល ផលកម្មរបស់គេចុះ ។ ឧបេក្ខាបែបនេះខុស ទស្សនគតិបែបនេះខុស ព្រះពុទ្ធមិនប្រដៅដូចនោះទេ។ បើក្នុងពេលដែលកម្មឲ្យផលជាសេចក្តីទុក្ខលំបាកដល់គេ ហើយយើងតាំងចិត្តជាឧបេក្ខា គឺព្រងើយកន្តើយ មិនជ្រៀតជ្រែកនាទីរបស់កម្ម ឧបេក្ខាបែបនេះត្រូវប៉ុន្តែបន្ទាប់ពីកម្មឲ្យផលជាសេចក្តីទុក្ខលំបាកមក យើងអាចប្រើមេត្តា ករុណាបាន បើមានលក្ខណៈត្រឹមត្រូវគួរនិងធ្វើដូចនោះ មិនមែនប្រើឧបេក្ខារហូតទេ ត្រូវប្រើមេត្តា ករុណាតាមសមគួរវិញ ទស្សគតិបែបនេះត្រូវ ។ ប្រសិនបើមានទស្សនគតិថា កម្មរបស់សត្វហើយប្រើឧបេក្ខារហូត ប្រហែលជាព្រះពុទ្ធមិនបាននិមន្តប្រោសសត្វទេ ហើយព្រះអង្គក៏មិនមានមេត្តា ករុណាគុណដែរ ។តែព្រះពុទ្ធអង្គ អត់ប្រើឧបេក្ខារហូតដូចជាពួកអ្នកភាន់ច្រឡំនោះទេ។ ម្យ៉ាងទៀត បើយើងឃើញនគរបាលបណ្តើរអ្នកទោសចេញមកធ្វើការ ហើយអ្នកទោសនោះស្រេកទឹក សុំទឹកយើងផឹក តើយើងប្រើឧបេក្ខា ឬប្រើមេត្តា ករុណា? ប្រសសិនបើគេអំពាវនាវថា អ្នកទោសក្នុងគុកកំពុងខ្វះខាត កន្ទេល ខ្នើយ មុង ត្រូវការជំនួយជាបន្ទាន់ តើយើងប្រឧបេក្ខា ឬប្រើមេត្តា ករុណា? សាវករបស់អន្សត្ថិរិយ៍គេប្រើឧបេក្ខាហើយ តែយើងជាសាវក សាវិកា របស់ព្រះពុទ្ធត្រូវប្រើមេត្តា ករុណា ។ ហេតុនេះ សូមពួកអ្នកដែលចង់ទៅនិព្វានឆាប់ជ្រុលពេកហ្នឹង មេត្តាងាកមើលមនុស្សលោក មើលប្រទេសជាតិយើងផង ក្រែងយើងមិនដល់និព្វានធ្លាក់ខ្លួនមកនៅត្រឹមកញ្ចះយួន ។

# តម្លៃនិយម

ការកំណត់តម្លៃ ឬការឲ្យតម្លៃ ហៅថា តម្លៃនិយម ។តម្លៃនិយមនេះ សំខាន់ណាស់ ព្រោះវាជាមនោកម្ម ។ បើគេឲ្យតម្លៃត្រូវ វាជួយធ្វើឲ្យសង្គមដើរទៅមុខស្រួល បើគេឲ្យតម្លៃខុស វាធ្វើឲ្យសង្គមមានបញ្ហាស្មុគស្មាញរហូតដល់ធ្វើឲ្យច្របូកច្របល់ដល់កម្មផលទៀតផង ។

សព្វថ្ងៃនេះ នៅស្រុកខ្មែរ យើង គេនិយមឲ្យតម្លៃទៅមនុស្សអ្នកមានបុណ្យសក្តិ អ្នកមានអំណាច ទោះបីអ្នកនោះជាមនុស្សទុច្ចរិត ប្រព្រឹត្តខុសដល់កម្រិតណាក៏ដោយ ក៏នៅតែលើកតម្កើងល្អថា ថាគ្រាន់បើម្លោះហើយ មនុស្សត្រូវតែស្វែងរកបុណ្យសក្តិ ស្វែងរកអំណាច ទោះបីដោយវិធីកាប់សម្លាប់ គេយកក្តីដោយវិធីលួចបន្លំសន្លឹកឆ្នោតក្តី ឬក៏ដោយវិធីសូកប៉ាន់ ទិញដូរគ្នាក្តី ធ្វើយ៉ាងណាឲ្យតែបានបុណ្យសក្តិ បានអំណាច គឺជាការត្រឹមត្រូវហើយ ។ម៉្យាងទៀត គេនាំគ្នាឲ្យតម្លៃទៅលើមនុស្សអ្នកមានមាសប្រាក់... គេយកមាសប្រាក់ជាធំ ជាចៅហ្វាយប្រាក់ប្រើមនុស្ស មិនមែនមនុស្សប្រើប្រាក់ទេ... គេធ្វើជាមុខឆ្អែ ស្រែជម្រៅ ឥតអៀនខ្មាសខ្វះហិរិ ឱត្តប្បៈ ធ្វើយ៉ាងណាឲ្យតែបានមាសប្រាក់ ទោះបីដោយវិធីលួចជាតិក្តី ដោយវិធីសង្កត់សង្កិនរាស្ត្រក្តី ឬក៏ដោយវិធីលក់ដូរជួញប្រែខុសច្បាប់ ខុសសីលធម៌ក្តី ឲ្យតែបានមាសប្រាក់ច្រើន គឺជាការត្រឹមត្រូវហើយ ។ការឲ្យតម្លៃនេះ ផ្ទុយនឹងពាក្យបុរាណថា សក្តិពុំស្មើយស នាអ្នកខ្ពង់ខ្ពស់ ពុំស្មើចិត្តជាវីរអ្នកមានយស សម្បូរគ្នីគ្នា សុទ្ធសឹងមិត្រភ្វា ជួយជាកម្លាំង។ការឲ្យតម្លៃនៅមានឧទាហរណ៍ច្រើនទៀត ដូចជាអ្នកណានៅពីលើច្បាប់បាន អ្នកនោះគ្រាន់បើ សុំទោស អ្នកណាមានស្រីច្រើន អ្នកនោះគ្រាន់បើ... សូមគិតរក ឧទាហរណ៍ ដោយខ្លួនឯងផ្សំទៀតចុះ ។ នេះការឲ្យតម្លៃខុស ។

ស្រុកខ្មែរ យើងសព្វថ្ងៃ វាធ្លាក់ខ្លួនចុះមកដល់ថ្នាក់ទាបជាមួយគ្នានឹងពួកប្រទេសធុនអន់បំផុតនៅទ្វីបអាហ្វ្រិក។ តើយើងគិតយ៉ាងម៉េច ឈ្លោះគ្នាតទៅគ្នា ឬក៏រួបរួមសាមគ្គីគ្នារំដោះជាតិ កសាងប្រទេសយើងឡើងវិញ? រឿងឈ្លោះគ្នា រឿងជានាគ្នា រឿងអស់នេះ ត្រូវរៀនសូត្រឲ្យម៉ត់ចត់ ត្រូវតែពិចារណាឲ្យច្បាស់លាស់ មិនមែនធ្វើងងិតងងល់ដូចជាខ្វាក់បានទេ ។ នៅសម័យសាធារណរដ្ឋខ្មែរ លន់ នល់ មានស្លោកមួយចែងថា “យួនឈ្លោះគ្នា ដីយួនរីក ខ្មែរឈ្លោះគ្នា ដីខ្មែររួម” រឿងនេះ ត្រូវគិត...។ អ្នកដឹកនាំខ្មែរសព្វថ្ងៃ ភាគច្រើនធ្លាប់ជាកូនសិស្សរបស់យួន ដូចនេះ បើដល់បទឈ្លោះគ្នា ត្រូវឈ្លោះឲ្យរីកទឹកដីដូចយួនអីចឹង បើបាត់ទឹកដីហ្នឹងខុសក្បួនគ្រូហើយ ។ ហើយបើដល់បទជានាគ្នា ក៏ត្រូវជានាឲ្យពិតប្រាកដ កុំឲ្យចាញ់បោកគេ ដូចប្រវត្តិសាស្ត្របានចែងទុកទៀត ។... ក្នុងពេលដែលស្តេចខ្មែរ យើងដណ្តើមអំណាចគ្នា ព្រះចៅពក្រពត្តិនៃក្រុងទេពមហានគរ បានលើកទ័ពចូលមកជួយផ្សះផ្សាឲ្យជានាគ្នាឡើងវិញ រវាងព្រះធម្មរាជា ព្រះស្រីរាជា និងព្រះសុរិយោទ័យ ទីបញ្ចប់ គេបោកយកព្រះស្រីរាជា និងព្រះសុរិយោទ័យ ដែលជាកូនខ្មែរសុទ្ធ ទៅឃុំទុកនៅក្រុងទេពមហានគររហូតទាល់តែសុវណ្ណគតហើយទុកឱកាសឲ្យព្រះធម្មរាជា កូនកាត់សៀម (ព្រះពញាយ៉ាត និងព្រះមេនាងស៊ីសាង៉ាម) សោយរាជ្យគ្រប់គ្រងប្រទេសកម្ពុជាតទៅ ។ ការជានាបែបនេះ ត្រូវប្រយ័ត្ន ... កុំជានាគ្នាក្រៅដំបៅក្នុង កុំជឿគេស្លុងឥតបញ្ញាគេបោកលើគោកអត់យល់ការ អួតអាងសង្ហាថាឯងគ្រាន់ ។ បើរួបរួមសាមគ្គីគ្នា កសាងប្រទេសយើងឡើងវិញ កុំភ្លេចអភិវឌ្ឍន៍សង្គម ដើម្បីអភិវឌ្ឍន៍សង្គម មុនបង្អស់ ត្រូវអភិវឌ្ឍន៍មនុស្ស អភិវឌ្ឍន៍តម្លៃនិយម ហើយកុំភ្លេចអភិវឌ្ឍន៍ព្រះសង្ឃ ព្រោះព្រះសង្ឃជាអ្នកដឹកនាំ ជាអ្នកនៅជិតនឹងប្រជាជន ។

## ឧបាសក ឧបាសិកា និង កម្មផល

កម្មផល មិនមែនជារឿងសម្រាប់តែឧបាសកឧបាសិកាទេ វាជារឿងរបស់មនុស្សទាំងអស់គ្នា នរណាៗក៏ធ្វើកម្ម នរណាៗក៏ត្រូវទទួលផលនៃកម្ម ដោយឥតប្រកែកបាន ទោះបីគេយល់ដឹងរឿងកម្មក្តី មិនយល់ដឹងក្តី បើគេធ្វើកម្មហើយ គេត្រូវតែទទួលផលនៃកម្មតាមច្បាប់របស់កម្ម ។ អ្នកកាន់ពុទ្ធសាសនា បើឡើងដល់ថ្នាក់ឧបាសក ឧបាសិកាហើយ គេត្រូវតែចេះដឹងទ្រឹស្តីកម្មផល ល្មមបដិបត្តិបាន ព្រោះថា បើគេបដិបត្តិខុសគេចុះតម្លៃផង ធ្វើឲ្យមានបញ្ហាដល់អ្នកឯទៀតផង បើគេបដិបត្តិត្រូវ គេមានតម្លៃផង ជាតិ សាសនា ចំរើនរុងរឿងផង ។ ព្រះពុទ្ធសម្តែងថា ឧបាសក ឧបាសិកាណាជឿមង្គលភ្ញាក់ផ្អើល ដូចជឿថា អ្នកមានបុណ្យផុសឯនេះឯនោះជាដើមក្តី

មិនជឿកម្មទៅជឿលើវត្ថុផ្សេងៗ ដូចចែកាច់ ខ្នាយតាន់ ថាជាមង្គល ឬរៀបចំធ្វើពិធីរំដោះគ្រោះ ឬធ្វើពិធីបួងសួងសុំសុខសប្បាយក្តី ឧបាសក ឧបាសិកា នោះឈ្មោះថា ចណ្ឌាល ឧបាសក ឧបាសិកា គឺ ឧបាសក ឧបាសិកាថោកទាប ... មិនជាបុគ្គលគួរប្រាថ្នាឡើយ ។ បើ ឧបាសក ឧបាសិកា ណាជឿកម្មផល ហើយបដិបត្តិត្រឹមត្រូវតាមធម៌វិន័យ ឧបាសក ឧបាសិកា នោះឈ្មោះថារតនឧបាសក ឧបាសិកា គឺឧបាសក ឧបាសិកាមាស ឧបាសក ឧបាសិកាពេជ្រ ជាបុគ្គលគួរលើកតម្កើងគោរពបូជា ។ សព្វថ្ងៃនេះ រតនឧបាសក ឧបាសិកា មានចំនួនតិចទេ ចណ្ឌាលឧបាសក ឧបាសិកា មានចំរើនច្រើនជាង ឯអ្នកដែលមិនប្រាកដជាកាន់សាសនានោះ រឹតតែច្រើនណាស់ទៅទៀត បានជាប្រទេសជាតិចេះតែវេចវិលលិចលង់ទៅងើបមុខមិនរួច ។

## ព្រះសង្ឃនិង កម្មផល

ព្រះសង្ឃជាសាវករៀមច្បងគេបំផុត ក្នុងការសិក្សា បដិបត្តិខ្លួនឯងផង ក្នុងការសម្តែងធម៌វិន័យប្រៀនប្រដៅអ្នកដទៃផង ។ គ្រហស្ថគេមានកិច្ចការច្រើន មិនសូវមានពេលសិក្សាធម៌វិន័យទេ លុះពេលណាមានទុក្ខធុរៈកើតឡើងទើបគេរត់មករកទីពឹងព្រះសង្ឃ ។ ព្រះសង្ឃត្រូវមានសេចក្តីស្មោះត្រង់ មានមេត្តា ករុណាសម្តែងប្រាប់សេចក្តីពិត បិទផ្លូវកំហុស ហើយឆ្លុះបំភ្លឺផ្លូវត្រូវ ផ្លូវនាំឲ្យកើតសេចក្តីសុខ សេចក្តីចំរើន ដល់គ្រហស្ថព្រោះគ្រហស្ថគេបានចិញ្ចឹម និងលើកតម្កើងព្រះសង្ឃខ្ពង់ខ្ពស់ណាស់ ។ ព្រះសង្ឃខ្លះ លោកជឿលើកម្មផលពិតប្រាកដ ។ លោកបដិបត្តិល្អត្រឹមត្រូវ លោកដឹកនាំក្នុងផ្លូវការកសាងជាតិ សាសនា ទៅរកសេចក្តីសុខ សេចក្តីចំរើន ព្រះសង្ឃដូចនេះ ត្រូវគោរពបូជា លើកតម្កើងថែរក្សាទុកជាទីសក្ការៈតអង្វែងទៅ ។ ប៉ុន្តែ មានព្រះសង្ឃមួយចំនួនទៀតបួសក្នុងពុទ្ធសាសនាហើយ មិនជឿលើកម្មផល ដើរប្រាប់ពន្យល់ផ្តេសផ្តាស ដឹកនាំធ្វើពិធីសែយសាស្ត្រំដោះគ្រោះថ្នាក់ លើករាសីជាដើម ឬក៏ដើរបោកបញ្ឆោត ប្រាប់លេខឆ្នោត លេខហួយ ទស្សន៍ទាយ ប្រកាន់ឬក្សពារវេលាអាក្រក់ល្អ អួតអាងខ្លាំងពូកែ កាប់មិនមុត ដុតមិនឆេះ ។ ព្រះសង្ឃបែបដំរីខ្វាក់ ទ្រមាក់ឆ្កួតនេះហើយ ដែលអូសទាញ រុញច្រានជាតិសាសនាឲ្យអប្បឱន លិចលង់ងើបមុខមិនរួច។ មិនតែប៉ុណ្ណោះ មានពួកអាចារ្យកំហូចខ្លះ ក៏ចូលដៃផ្សំស៊ីជាមួយពួកព្រះសង្ឃអលជ្ជីនោះដែរ ។ ពួកអស់នេះ សុទ្ធតែជាមេរោគឧត្បាតបំផ្លាញជាតិសាសនា ដែលត្រូវតែចាត់ការបោសសម្អាតចោលឲ្យអស់ពីសង្គមខ្មែរ ។

## សម្តេចសង្ឃនាយកនិង ក្រសួងធម្មការ

ពីដើម អ្នកដឹកនាំផ្នែកព្រះសង្ឃ គេហៅថា សម្តេចព្រះសង្ឃនាយក យូរៗ មានឡើងជាសម្តេចសង្ឃរាជម្តង ប៉ុន្តែ សម័យសព្វថ្ងៃ គេនិយមសម្តេចព្រះសង្ឃរាជ។សម្តេចសង្ឃនាយក ឬសម្តេចព្រះសង្ឃរាជ ដោយមានក្រសួងធម្មការ មេគណ អនុគណ ចៅអធិការ ជាសហការី មាននាទីដឹកនាំព្រះសង្ឃ ឧបាសក ឧបាសិកា ឲ្យបដិបត្តិត្រឹមត្រូវតាមធម៌វិន័យ ជួយសាងជាតិ សាសនាឲ្យសុខសប្បាយចំរើនលូតលាស់ ថ្កុំថ្កើងរុងរឿងសមស្របតាមធម៌វិន័យដែលព្រះសង្ឃអាចជួយបាន ។

បច្ចុប្បន្នេះ ព្រះសង្ឃល្អ កាន់ធម៌វិន័យ ជួយសាងជាតិ សាសនា ជាព្រះសង្ឃគួរគោរពបូជាក៏មានព្រះសង្ឃអប្រិយ ចង្រៃបំពុលពង្វក់ឧបាសកឧបាសិកា និងប្រជាជនឲ្យជឿផ្តេសផ្តាសក៏មានដែរ តែអ្នកគ្រប់គ្រងហាក់ដូចមើលមិនសូវឃើញ...។ សូមកុំមើលស្រាល កុំចង់បានថ្នូរជាអ្វីៗទោះបីជាសាលារៀនពីព្រះសង្ឃផ្តេសផ្តាសនោះ ព្រោះការ ពង្វក់មនុស្សឲ្យជឿផ្តេសផ្តាសនោះ វាស៊ីជម្រៅវាខ្លាំងជាង មិនងាយគាស់ល្បើក

មិនងាយកសាងជាតិ សាសនា ឲ្យចំរើនជឿនលឿនបានទេ ស្រុកទេសធ្លាក់ខ្លួនដល់ថ្នាក់ម្នឹងទៅហើយ នៅស្រមើស្រមៃរងចាំអ្នកមានបុណ្យ ចេញពីរូងភ្នំមកជួយភ្លេចជួយខ្លួនឯង ។

## ស្លាប់ហើយកើតទៀតឬទេ ?

សាសនាខ្លះថា ស្លាប់ហើយមិនកើតទៀតទេ វារលួយរលេះ ឬគេដុតទៅជាផេះអស់ហើយ មិនឃើញមានអ្វីកើតទៀតទេ វាចប់ត្រឹមប៉ុណ្ណឹងហើយ គ្មានកម្មផល បាបបុណ្យ អីឯណាទៀតទេ ធ្វើល្អ ធ្វើអាក្រក់ក៏គ្មានផលអីទៀតទេ គឺវាចប់ត្រឹមស្លាប់ហ្នឹងហើយ ។ បើគ្មានបាប គ្មានបុណ្យ នរណាចង់ធ្វើអីធ្វើតាមចិត្តជាប់អ្នកខ្សោយអស់ហើយ ។

សាសនាខ្លះថា ស្លាប់ហើយមិនកើតទៀតទេ តែត្រូវទៅរងចាំព្រះជាម្ចាស់លោកកាត់សេចក្ដីឲ្យឡើងស្ថានសួគ៌ឬឲ្យចុះនរក ។ សាសនានេះ ស្រេចតែព្រះជាម្ចាស់ ខ្លួនឯងគ្មានបានការអីទេ នាំគ្នាទៅដេកចាំព្រះជាម្ចាស់ចុះ នរណាត្រូវព្រះឲ្យចុះនរកស៊យធំហើយ ។

សាសនាខ្លះទៀតថា ស្លាប់ហើយត្រូវកើតទៀត តែធ្លាប់កើតយ៉ាងម៉េច កើតអីចឹងទៀត ។ អ្នកណាកើតមកមិនសមប្រកបស៊យធំហើយ ព្រោះអត់មានវិធីកែទេ ។

ពុទ្ធសាសនាថា សង្ខារធម៌ទាំងអស់មិនទៀង សុទ្ធតែប្រព្រឹត្តទៅតាមហេតុបច្ច័យទាំងអស់ ។ រឿងកើតស្លាប់ ព្រះពុទ្ធសម្ដែងថា ម្នាលភិក្ខុទាំងឡាយ ដូចដំបងដែលគេចោលទៅឰដ៏អាកាស ជួនកាលធ្លាក់ចុះខាងគល់មកមុន ជួនកាលធ្លាក់ចុះត្រង់កណ្ដាលមកមុន ជួនកាលធ្លាក់ចុះខាងចុងមកមុន ពួកសត្វដែលមានអវិជ្ជាជាទំនប់មានតណ្ហាជាចំណង តែងត្រាច់រង្គាត់ពិភពលោកនេះទៅលោកខាងមុខ ជួនកាលត្រាច់ពីលោកខាងមុខមកកាន់លោកនេះវិញ សង្សារការវិលវល់កើតស្លាប់មិនមានទីបំផុតដែលគេដឹងបាន មិនគួរឲ្យសប្បាយរីករាយគួរឲ្យនឿយណាយ ធុញទ្រាន់ពន់ពេក[៩] ។

រឿងកើត ស្លាប់ ត្រូវប្រព្រឹត្តទៅតាមហេតុបច្ច័យ បើកិលេសគឺអវិជ្ជា តណ្ហា ជាហេតុនាំឲ្យកើតនៅមានដូចជាពួកយើងបុថុជ្ជននេះ ស្លាប់ហើយត្រូវតែកើតទៀត បើកិលេសគឺអវិជ្ជា តណ្ហា ជាហេតុនាំឲ្យកើតរលត់អស់ហើយ ដូចជាពួកព្រះអរិយៈ ស្លាប់ហើយមិនមានការកើតតទៅទៀតទេ ត្រូវនិព្វានជាទីបញ្ចប់ទុក្ខត្រឹមនេះឯង ។ ឯពួកអ្នកដែលស្លាប់ហើយនៅកើតតទៅទៀតគេត្រូវប្រព្រឹត្តទៅតាមហេតុបច្ច័យ គឺកម្មផលទាំងអស់អត់មានអ្នកណាអាចប្រកែកបានទេ ប៉ុន្តែ គេអាចកែលំអកសាងខ្លួន រើបម្រះខ្លួនខ្ពស់ឡើងៗ ដោយវិធីធ្វើតែកម្មល្អឲ្យច្រើនឡើងៗ បាន ។

រឿង កើត ស្លាប់ នេះ បើស្លាប់ហើយសូន្យ មិនកើតទៀតទេ ការធ្វើបុណ្យកុសល ឬអ្នកកសាងជាពុទ្ធភូមិដើម្បីបានត្រាស់ជាព្រះពុទ្ធក៏គ្មានដែរ ។ ប្រើសិនបើមានអ្នកបានត្រាស់ជាព្រះពុទ្ធ ដោយមិនចាំបាច់កសាងអ្វីការសម្ដែងធម៌ល្អ អាក្រក់របស់ព្រះពុទ្ធអង្គនោះ ក៏គ្មានន័យអ្វីដែរ អដ្ឋង្គិកមគ្គ ផ្លូវទៅកាន់ព្រះនិព្វាន ក៏មិនមានប្រយោជន៍អ្វីដែរ ព្រោះរឿងវាត្រូវចប់ត្រឹមស្លាប់ ដោយមិនមានការកើតទៀតស្មើភាពគ្នា ដូចគ្នាទាំងអស់ ។

ហេតុនេះ អ្នកមានបញ្ញា គប្បីពិចារណាឲ្យបានល្អប្រពៃចុះ ។

---

[៩] សុត្តន្តបិដកសំយុត្តនិកាយ និទានវគ្គ ៣២-១០៦-៩២។

# អ្វីទៅកើតទៀត ?

កម្មល្អ អាក្រក់ទាំងឡាយ ដែលគេបានធ្វើ ក្រោយពីវាបានកើតឡើងហើយ វាមិនទាន់បាត់បង់សោះសូន្យទៅណាទេ បើជាកម្មអាក្រក់ វាទៅកករួមផ្សំជាមួយគ្នានឹងកិលេសចាស់ ជាអនុស័យកិលេស បើជាកម្មល្អ វាទៅរួមផ្សំគ្នានឹងបុណ្យកុសលចាស់ជាឧបនិស្ស័យ កាន់តែប្រសើរឡើង ច្រើនឡើងៗ ជាលំដាប់ លុះដល់ពេលវាទុំ វានឹងចេញមកឲ្យផល តាមកាលដ៏សមគួររបស់វា ។ មនុស្សយើងក្នុងពេលជិតស្លាប់ចិត្តចុងក្រោយបំផុតហៅថា ចុតិចិត្ត ឬចុតិវិញ្ញាណតែងតែឃើញនូវអារម្មណ៍ទាំង ៣ គឺកម្មារម្មណ៍ កម្មនិមិត្តារម្មណ៍ គតិមិត្តារម្មណ៍ឬហៅខ្លីថា កម្ម កម្មនិមិត្ត គតិនិមិត្ត ឯណានីមួយ លុះឃើញហើយក៏ចាប់អារម្មណ៍នោះជាប់ មុននឹងចុតិវិញ្ញាណរលត់ទៅ វាបានប្រគល់អារម្មណ៍ដែលមានតួនាទីទៅចាប់ភពថ្មីទៀត ។ ព្រះលោកនាថសម្តែងទុកថា ៖

**កម្មំ ខេត្តំ វិញ្ញាណំ ពីជំ សិនេហោ អវិជ្ជា នីវរណានំ សត្តានំ តណ្ហាសំយោជនានំ ហីនាយ ធាតុយា វិញ្ញាណំ បតិដ្ឋិតំ ឯវំ អាយតឹបុនព្ភវាភិនិព្វត្តិ ហោតិ ។**

ប្រែថា កម្មជាស្រែ វិញ្ញាណជាពូជ តណ្ហាជាទឹក វិញ្ញាណរបស់ពួកសត្វ ដែលមានអវិជ្ជាជាទំនប់នៅសើបហើយក្នុងធាតុដ៏ថោកទាប (កាមធាតុ) ការកើតឡើងចំពោះក្នុងភពថ្មី តទៅទៀត រមែងមានយ៉ាងនេះ ១០។

# អារម្មណ៍ ៣ យ៉ាង

១-**កម្មារម្មណ៍** អារម្មណ៍គឺការងារដែលខ្លួនធ្លាប់ធ្វើ បើខាងកុសល គឺឃើញខ្លួនឯងកំពុងធ្វើទាន រក្សាសីល -ល- បើខាងអកុសល គឺឃើញខ្លួនឯងកំពុងសម្លាប់សត្វ លួចទ្រព្យគេជាដើម មិនមែនឃើញដោយភ្នែកទេ គឺឃើញដោយមនោទ្វារ (ចិត្ត) ។

២-**កម្មនិមិត្តារម្មណ៍** អារម្មណ៍គឺគ្រឿងប្រដាប់សម្រាប់ធ្វើការងារ បើខាងកុសល គឺឃើញត្រៃចីវរ កុដិ សាលា ព្រះវិហារ -ល- បើខាងអកុសល គឺឃើញដាវ លំពែង សំណាញ់ មងជាដើម ។ កម្មនិមិត្តមាន ២ គឺអតីតកម្មនិមិត្ត ឃើញតាមមនោទ្វារ (ចិត្ត) បច្ចុប្បន្នកម្មនិមិត្ត គឺឃើញតាមបញ្ចទ្វារ ភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ ។

៣-**គតិនិមិត្តារម្មណ៍** អារម្មណ៍គឺកន្លែងដែលគេត្រូវធ្វើដំណើរទៅ បើខាងកុសល គឺឃើញប្រាសាទ រាជវាំង ស្ថានសួគ៌ -ល- បើខាងអកុសល គឺឃើញទីកន្លែងគួរឲ្យភ័យខ្លាច ឃើញស្ថាននរក ជាដើម គឺឃើញតាមមនោទ្វារ (ចិត្ត) ។ កម្មដែលមកប្រាកដជាអារម្មណ៍នោះ មិនបានកំណត់ដាច់ខាតថា កម្មថ្មី ឬកម្មចាស់នោះទេ បើមានគរុកម្ម ៗនោះ ត្រូវតែមកប្រាកដជាអារម្មណ៍ឲ្យឃើញ បើមិនមានគរុកម្មទេ អាសន្នកម្ម ឬអាចិណ្ណកម្ម មានកម្លាំងខ្សោយ កម្មចាស់ដែលរង់ចាំពេលវេលាមកអស់កាលដ៏យូរ ហើយនោះមានកម្លាំងខ្លាំងជាង វាត្រូវតែចេញមកប្រាកដជា អារម្មណ៍ជំនួសវិញ ចុតិវិញ្ញាណចាប់យកអា រម្មណ៍នោះ

---

[១០] សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត ៤១-៧៨-៣០៤ ។

ហើយប្រគល់ឲ្យជំនួសវិញ ចុតិវិញ្ញាណយកទៅចាប់ភពថ្មីទៀត បើគេឃើញអារម្មណ៍ជាកុសល គេនឹងទៅកើតក្នុងសុគតិ បើគេឃើញអារម្មណ៍ជាអកុសល គេនឹងទៅកើត ក្នុងអបាយភូមិ ។

ហេតុនេះ គេត្រូវតែខំព្យាយាមលះអកុសលកម្ម ហើយកសាងសន្សំកុសលកម្មឲ្យច្រើនឡើងៗ ដើម្បីជួយឲ្យមានអារម្មណ៍ល្អៗ កើតឡើងក្នុងពេលជិតស្លាប់ទើបជាការប្រសើរ ៕

## នត្ថិ កាម្មសមំ ពលំ

*គ្មានកម្លាំងអ្វី ខ្លាំងស្មើនឹងកម្លាំងកម្មឡើយ ។*

## ៣៖ ឆ្នាំថ្មី

ឆ្នាំថ្មីចូលមក ដល់ទៀតហើយ បងប្អូនខ្មែរអើយ គ្រប់រូបា
អ្នកក្រុងអ្នកស្រែ អ្នកចំការ ចូរពិចារណា ឲ្យម៉ត់ចត់។
ថ្ងៃ ខែ និង ឆ្នាំ ជាវេលា ដែលបណ្ឌិតា លោកកំណត់
ជាគ្រឿងចំណាំ ចាំចារកត់ ទុកជាសន្មត តាមលោកីយ។
អ្នកមានបញ្ញា ភ្លឺថ្លាស្អាត ខិតខំសង្វាត ខំឃ្មាតខ្មី
ប្រឹងធ្វើការងារ កាប់គាស់ដី ទិញលក់ដូរអ្វី បានចំរើន ។
អ្នកឥតបញ្ញា ងងិតឈឹង ដេកស្ងៀមរំពឹង ចង់បានច្រើន
បន់ទេព្តាថ្មី ក្រែងកបកើន មិនបានចំរើន ទេអ្នកអើយ ។
យើងត្រូវពឹងកម្ម គឺការងារ ពិតជាវានឹង ជួយយើងហើយ
បានទ្រព្យសម្បត្តិ មិនខ្វះឡើយ បងប្អូនខ្មែរអើយ ចូរពឹងកម្ម ៕

## ត្រូវជឿកម្មផល

យើងអ្នកកាន់ពុទ្ធសាសនា    ត្រូដឹកនាំគ្នាជឿកម្មផល
ដែលព្រះទ្រង់ញាណទសពល    សម្តែងពន្យល់ដល់សព្វសត្វ។
កម្មគឺអំពើដែលយើងធ្វើ    ចេតនាអើពើបដិបត្តិ
ដោយកាយវាចាឬដោយចិត្ត    អាក្រក់ល្អពិតហៅថាកម្ម។
បើមានកម្មហើយត្រូវមានផល    ត្រឡប់មកដល់ជាប្រចាំ
ទោះបីយូរថ្ងៃ ខែ ឬឆ្នាំ    គង់តែកម្មឲ្យផលជាពុំខាន។
ធ្វើល្អបានល្អតទៅមុខ    ផុតទុក្ខបានសុខចិត្តក្សេមក្សាន្ត
ធ្វើបាបអាក្រក់ទាំងប៉ុន្មាន    គង់តែងនឹងបានទុក្ខទោសទណ្ឌ។
សុខទុក្ខកើតមកពីយើងធ្វើ    មិនមែនមកពីការបន់ស្រន់
អារក្សអ្នកតា អ្នកមានបុណ្យ    ចូលរូបបញ្ជាន់មកសណ្ឋិត។
ល្បិចកលបញ្ឆោតនិងបោកប្រាស់    ភូតភរផ្តេសផ្តាសឥតមានពិត
អ្នកអប្បបញ្ញាថា ស័ក្តិសិទ្ធិ    តែតាមរឿងពិតគឺឆោតល្ងង់។
កុំជឿបែបនេះតទៅទៀត    នាំជាតិសាសនាយើងលិចលង់
ត្រូវជឿកម្មផលទើបរឿងរុង    ផុតផុងភិតភ័យស្បើយទុក្ខា។
ព្រះសង្ឃកុំនាំគេផ្តេសផ្តាស    ប្រាសធម៌វិន័យព្រះសាស្តា
ត្រូវជួយសាងជាតិខេមរា    ឲ្យថ្កើងថ្លៃថ្លាអង្វែងទៅ ៕

## កុំបន់ស្រន់

បន់ស្រន់បួងសួងអស់ទេព្តា អារក្សអ្នកតាខ្មោចបិសាច
គេជឿថាមានឫទ្ធិអំណាច ពូកែអង់អាចជួយគេបាន។
វាមិនដែលពិតដូចនោះសោះ នាំឲ្យតែអស់ទ្រព្យធនធាន
ខាតពេលវេលានាំរំខាន មិនដែលឃើញបានប្រយោជន៍អ្វី ។
រឿងបន់ស្រន់នេះព្រះសម្ពុទ្ធ ដែលជាមកុដផុតលោកិយ
បានត្រាស់ដឹងច្បាស់សព្វសេចក្តី ថាគ្មានបានអ្វីត្រូវឈប់បន់។
បើអ្នកមិនជឿចូរសាកល្បង នាំអស់ញាតិផងជួយបន់ស្រន់
បន់ឲ្យដុំថ្មមានទម្ងន់ អណ្តែតលើលន់លើទឹកបាន។
ឬបន់ឲ្យប្រេងលិចទឹកទៅ កុំឲ្យស្ថិតនៅនាំរំខាន
គេប្រើប្រាស់ទឹកមិនសូវបាន មេត្តាជួយប្រាណឲ្យលិចទឹក ។
បើអ្នកអាចបន់ដូចនេះបាន សមតាមលំអានដែលអ្នកនឹក
ឃើញច្បាស់ស័ក្តិសិទ្ធិពិតសន្លឹក នាំគ្នាភ្លូតភ្លឹកបន់ទៀតចុះ ។
បើបន់ទៅហើយមិនបានការ អ្នកមានបញ្ញាទាំងប្រុសស្រី
ត្រូវពិចារណារកត្រូវខុស ចប់ត្រឹមហ្នឹងចុះរឿងបន់ស្រន់ ៕

## កុំជឿពេលវេលា

កុំប្រកាន់ជឿពេលវេលា ថាថ្ងៃល្អជាថ្ងៃចង្រៃ
ឲ្យលាភឲ្យសុខឲ្យទុក្ខភ័យ តាមពិតថ្ងៃខែឆ្នាំធម្មតា ។
អ្នកជឿថ្ងៃ ខែ ខូចប្រយោជន៍ នាំឲ្យហិនហោចខាតកិច្ចការ
ប្រយោជន៍កើតឡើងវេលាណា ជានក្ខត្តាឫក្សពារពិត ។
ព្រះពុទ្ធគោត្តមសម្តែងថា បើពួកសត្វណាធ្វើសុច្ចរិត
ស្អាតបាតដោយកាយវាចិត្ត ព្រឹកត្រង់ល្ងាចពិតពេលល្អហើយ ។
ចូរអ្នកទាំងឡាយភ្ញាក់រឭក ធ្វើការយប់ព្រឹកកុំកន្តើយ
យកសុចរិតជាគោលហើយ នឹងបានសុខស្បើយជោគជយា ៕

## កុំជឿមង្គលប្លម

កុំជឿស្លឹកមៀនស្លឹកឫស្សី ឬវត្ថុអ្វីជាមង្គល
នាំយើងឲ្យបានលាភភោគផល បានសុខថ្កើងថ្កល់សិរិសួស្តី ។
ជឿឆ្មេចដូចនេះមិនល្អទេ នាំយើងនាំគេឲ្យអប្រិយ
ខាតពេលខូចទ្រព្យបាតស្មារតី គ្មានបានការអ្វីឈប់ជឿទៅ ។
ព្រះពុទ្ធជាម្ចាស់សម្តែងថា ត្រូវមានបញ្ញាស្គាល់រាកជ្រៅ

ស្គាល់ភូតស្គាល់មែនស្គាល់ខុសត្រូវ ស្គាល់ណាជាផ្លូវមានមង្គល។
កុំចូលចិត្តសេពគប់ជនពាល វានាំបណ្តាលឲ្យវិលវល់
វង្វេងធ្វើតែអកុសល នាំទុក្ខជាផលឥតស្រាកស្រាន្ត ។
សេពគប់គោរពតែបណ្ឌិត កាយវាចាចិត្តល្អកល្យាណ
តែងជួយទឹកនាំយើងគ្រប់ប្រាណ បានសុខក្សេមក្សាន្តសិរីសួស្តី ។
មង្គលកើតពីយើងធ្វើល្អ ប្រព្រឹត្តតាមធម៌ព្រះជិនស្រី
មង្គលមានសាមសិបប្រាំបី សម្រាយបាលីមានហើយស្រាប់។
សូមបងប្អូនខ្មែរភ្ញាក់រឭក គគ្រេងគគ្រឹកយ៉ាងប្រញាប់
សាងជាតិសាសនាឲ្យបានឆាប់ ដើរតាមក្បួនច្បាប់មង្គលអើយ ៕

## កុំគ្រាន់តែប្រាថ្នា

មនុស្សយើងចូលចិត្តប្រាថ្នាណាស់ ទាំងក្មេងទាំងចាស់ប្រុសឬស្រី
ប្រាថ្នាសម្បត្តិក្នុងលោកិយ ចង់បានអ្វីៗ តែគ្រប់គ្នា ។
ប្រាថ្នាមាសប្រាក់ ឬស័ក្តិយស ប្រាថ្នាឋានខ្ពស់សុខសួគ៌ា
ប្រាថ្នានិព្វានហួសពណ៌នា តើអ្នករាល់គ្នាយល់ថាម៉េច ។
ព្រះពុទ្ធជាម្ចាស់សម្តែងថា បើសត្វប្រាថ្នាបានសម្រេច
ដូចក្តីបំណងសត្វសេចគ្រេច តើហេតុដូចម្តេចបានជាក្រ ។
ប្រាថ្នាតែម៉្យាងមិនប្រពៃ ត្រូវខំលកលៃធ្វើការល្អ
ទើបបានសម្រេចផលបវរ ជាទីត្រេកអរពិតពុំខាន ។
មេមាន់ប្រាថ្នាឲ្យកូនញាស់ មិនក្រាបពងសោះតាមលំអាន
តើកូនមាន់ណាអាចញាស់បាន មនុស្សគ្រប់ប្រាណគប្បីយល់ ។
មេមាន់មិនមានប្រាថ្នាសោះ តែក្រាបពងសោះសព្វឥតសល់
ដល់ពេលកូនញាស់មិនបាច់ខ្វល់ ញាស់អស់គ្មានសល់ទេអ្នកអើយ។
ផលល្អអាក្រក់មកពីធ្វើ ខុសត្រូវអំពើនេះឯងហើយ
មិនមែនមកពីប្រាថ្នាឡើយ អ្នករាល់គ្នាអើយយល់ឲ្យច្បាស់ ។
បើប្រាថ្នាល្អ ធ្វើត្រូវផង ដើរតាមទំនងព្រះជាម្ចាស់
ប្រាថ្នាហើយធ្វើឆាប់រហ័ស សម្រេចជាក់ច្បាស់មិនទាស់ទេ ៕

**"ចប់"**

សៀវភៅដែលរៀបរៀងដោយ **ព្រះមហាថេរៈខិន តេន ឥន្ទប្បញ្ញោ**

| | |
|---|---|
| ១-មង្គលសូត្តគាថា និង បរាភវសូត្ត | ឆ្នាំ ១៩៩២ |
| ២-ពុទ្ធវាទសង្ខេប | ឆ្នាំ ១៩៩៤ |
| ៣-ប្រស្នាអដ្ឋង្គិកមគ្គ | ឆ្នាំ ១៩៩៤ |
| ៤-សមថសង្ខេប | ឆ្នាំ ១៩៩៤ |
| ៥-វិបស្សនាសង្ខេប | ឆ្នាំ ១៩៩៤ |
| ៦-កំណាព្យរស្មីជីវិត | ឆ្នាំ ១៩៩៥ |
| ៧-ខន្ធ ៥ | ឆ្នាំ ១៩៩៦ |
| ៨-ឧបករណ៍វិបស្សនា | ឆ្នាំ ១៩៩៨ |
| ៩-សេចក្ដីមិនប្រមាទ | ឆ្នាំ ២០០០ |
| ១០-កម្មផល | ឆ្នាំ ២០០០ |
| ១១-ពុទ្ធសាសនារុងរឿង ឬរោយរៀវ | ឆ្នាំ ២០០២ |
| ១២-ប្រាថ្នាសមថ និងវិបស្សនាភាគ ១,២,៣, | ឆ្នាំ ២០០២ |
| ១៣-បាប និង បុណ្យ | ឆ្នាំ ២០០៣ |
| ១៤-កើត ស្លាប់ | ឆ្នាំ ២០០៤ |
| ១៥-ដៃគូអ្នកកាន់ពុទ្ធសាសនា | ឆ្នាំ ២០០៤ |
| ១៦-យើងអាចចំរើនអាយុបាន និងកំណាព្យ | ឆ្នាំ ២០០៦ |
| ១៧ហិនយាន មហាយាន | ឆ្នាំ ២០០៧ |
| ១៨-ខ្មែរមានពូជ | ឆ្នាំ ២០០៧ |

សៀវភៅទាំងប៉ុន្មាននេះ តាមពិតគឺគ្រាន់តែជាការបានស្គាល់របស់ខ្ញុំខ្លះៗ តែ ប៉ុណ្ណោះ បើតាមខ្ញុំដឹងគឺលោកសរសេរនិងបោះពុម្ពដើម្បីចែកជាធម្មទានជារៀងរាល់ឆ្នាំ អាចនិយាយបានថា នៅមានច្រើនជាងនេះទៀតដែលយើងមិនអាចដឹងអស់បាន ។

កូនសៀវភៅនេះ ខ្ញុំទទួលបាននៅឆ្នាំ ២០០៣ ហើយរក្សាទុករហូត។ ខ្ញុំគិតថានូវរាល់សៀវភៅ ដែលជាស្នាដៃនិពន្ធដោយព្រះមហាថេរៈងិន ភេន ឥន្ទប្បញ្ញោ គឺជាស្នាដៃដែលល្អជាង គេក្នុងចំណោម ស្នាដៃនិពន្ធអ្នកដទៃផ្សេងៗទៀត ។ មិនមែនថាខ្ញុំអគតិព្រោះស្រឡាញ់ ឬព្រោះស្អប់ខ្ពើមលើបុគ្គលណាម្នាក់ នោះទេ ប៉ុន្តែ ខ្ញុំមានគតិពីរបីរឃ្លា ចង់លើកឡើងដើម្បីទុកឲ្យអស់លោកអ្នកបានជាទីពិចារណាខ្លះៗ ថា ៖ ក្នុងសង្គមមួយដែលមានមនុស្សរាប់សិបហ្មឺនពាក់ កម្រនិងមានអ្នកប្រាជ្ញ កើតឡើងណាស់ ប៉ុន្តែ នៅពេលដែលមានអ្នកប្រាជ្ញប្រាកដ ខ្លួនមានឡើងហើយ តែបែរជាគេមិនស្គាល់ បើគេស្គាល់ហើយ តែបែរជាគេមិនទទួលស្គាល់ បើគេទទួលស្គាល់ហើយ តែបែរជាគេមិនឲ្យតម្លៃ ។តួយ៉ាងដូចជាព្រះថេរៈ មួយអង្គនេះជាដើម ។ សម្រាប់ខ្ញុំៗត្រឹមតែមានអារម្មណ៍ថា សោកស្ដាយតែប៉ុណ្ណោះ ។

ខ្ញុំសូមឧទ្ទិសចំណែកបុណ្យកុសលនេះ ប្រគេនជូនចំពោះវិញ្ញាណក្ខន្ធ នៃលោកអ្នកមាន គុណទាំងឡាយ មានគ្រូឧបជ្ឈាយាចារ្យ និង មាតាបិតាជាដើមផង ព្រមទាំងញាតិមិត្ត ទាំងឡាយផង ។ សូមលោកអ្នកដ៏មានគុណ ជាដើមនោះ អនុមោទនាទទួលយកនូវឥដ្ឋមនុញ្ញផលជាទីគាប់ចិត្ត តាមសេចក្ដី ប្រាថ្នារៀងៗខ្លួនកុំបីអាក់ខានឡើយ ៕ ៚

*នូវរាល់កំហុសឆ្គងដែលកើតឡើងដោយអចេតនាអំពីការវាយពុម្ពបញ្ចូលនេះ*
*សូមអស់លោកអ្នកជួយកែលម្អឲ្យបានត្រឹមត្រូវឡើងវិញផង។អរគុណ*!!!

នគរបឋម, ថ្ងៃសៅរ៍ ១២ កើត ខែផល្គុន ព.ស.២៥៥៦
ត្រូវនិងថ្ងៃទី ២៣ ខែមីនា គ.ស.២០១៣

អគ្គធរោ អ៊ុំម ឧត្ដម
អ៊ីមែល ៖ udom_student@hotmail.com,